# ជំនួយសុខភាពផ្លូវចិត្ត

# ភាគ ៣




រៀបរៀងដោយ

សាមណេរ ធម្មាលង្ការោ

**ចាន់ សុជន**

**សព្វទានំ ធម្មទានំ ជិនាតិ**

ក

# នមស្សការព្រះរតនត្រ័យ

⇨⇨ ⚜ ⇦⇦

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះសម្មា-សម្ពុទ្ធអង្គនោះ ដែលព្រះអង្គប្រៀបដូចអ្នកកាន់ប្រទីបបំភ្លឺលោកនេះ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះសទ្ធម្ម ដែលព្រះសទ្ធម្មនោះ ប្រៀបដូចប្រទីបបំភ្លឺលោកនេះ ឲ្យភ្លឺស្វាងឡើង។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះសង្ឃ ដែលព្រះសង្ឃនោះ ប្រៀបដូចលោកនេះ ដែលភ្លឺស្វាងចាកងងឹត ។

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ស្មើដោយត្បូងរបស់ខ្ញុំព្រះករុណា ។

ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ។

# ២

# ពាក្យប្រារព្ធ

➪➪ ⚜ ⇦⇦

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ! ឥឡូវនេះតថាគត ប្រាប់អ្នកទាំងឡាយឲ្យដឹង! សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ ។ នេះជាបច្ឆឹម វាចារបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គសម្ដែងនៅពេលដែល ព្រះអង្គទៀបនឹងបរិនិព្វាន ដោយអនុបាទិសេសនិព្វាន ។

ពុទ្ធបរិស័ទយើង មានចំណុចខ្វះខាតដោយន្លើដោយសារតែមិនបានសិក្សារៀនសូត្រ ព្រះធម៌ឲ្យបានជម្រៅ ។ តាមពិត ការដែលបដិបត្តិខ្លួន ឲ្យជាឧបាសកឧបាសិកា ឬ ពុទ្ធបរិស័ទ ឲ្យពិតប្រាកដនោះ មិនមែននៅត្រង់សណ្ឋាន ទ្រង់ទ្រាយខាងក្រៅនោះទេ គឺនៅក្នុងចិត្តសន្តាន ដែលបានទទួលយកព្រះធម៌មកដាក់ក្នុងខ្លួន ឲ្យបានជ្រួតជ្រាបយល់ច្បាស់លាស់អំពីហេតុផល ។

ដូច្នេះ ពុទ្ធបរិស័ទគប្បីសិក្សា ស្តាប់ ពិចារណា ស្វែងយល់ អំពីសេចក្តីដែលមាននៅក្នុងព្រះពុទ្ធសាសនា ដោយការត្រាស់ដឹង និងការប្រកាសសម្តែងរបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។

វត្តសំពៅមាស,ថ្ងៃទី ១៤ កើត ខែចេត្រ ព.ស ២៥៥០

សាមណេរ ធម្មាលង្ការោ **ចាន់ សុជន**

ឃ

# ឧទ្ទិសកថា

⇨⇨ ⚘ ⇦⇦

កុសលចេតនា របស់ខ្ញុំព្រះករុណា អាត្មាភាព ដែលបានរៀបរៀងសៀវភៅ **ជំនួយសុខភាពផ្លូវចិត្ត ភាគ ៣** នេះ ខ្ញុំព្រះករុណា អាត្មាភាព សូមគោរពដឹងគុណចំពោះព្រះរតនត្រ័យ និងមាតាបិតា ដែលបានផ្ដល់កំណើតឲ្យខ្ញុំ ។

ម្យ៉ាងវិញទៀត សៀវភៅនេះ ប្រសូតចេញពីការសិក្សារៀនសូត្រ ព្រះធម៌ ព្រះវិន័យ របស់ព្រះជិនស្រី ដែលព្រះអង្គទ្រង់ត្រាស់សម្ដែងហើយ ។ ជាពិសេសជាក់ស្ដែងក្នុងបច្ចុប្បន្ននេះ គឺបានទទួលការសិក្សារៀនសូត្រស្ដាប់ពីសំណាក់លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។

ដូច្នេះ ខ្ញុំសូមគោរព ប្រគេនបុណ្យ និងជូនបុណ្យចំពោះអ្នកមានគុណ ដូចមានឈ្មោះខាងក្រោមនេះ ៖

-លោកឪពុក ចាន់ សាមឿន

-អ្នកម្ដាយ ឃួន សាខន

-ព្រះឧបជ្ឈាយ៍ កណ្ឌរណ្ណោ ប៉ុក វុន

-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

-ព្រះគ្រូធម្មាចារ្យ សោភណត្ថេរោ សោម សុភាព

-លោកគ្រូធម្មាចារ្យ រស់ សុផាត

-ព្រមទាំងជូនបុណ្យ ចំពោះសព្វសត្វទាំងឡាយ ក្នុងសង្សារវដ្ត សូមជ្រះថ្លា ត្រេកអរអនុមោទនា ឲ្យបានគ្រប់ៗគ្នា ។

*សូមអនុមោទនា !!!*

# សារបណ្ណ

**អត្ថបទធម៌** **ទំព័រ**

-នមស្សការព្រះត្រៃរតន៍...................................... ក
-ពាក្យប្រារព្ធ................................................... ខ
-ឧទ្ទិសកថា..................................................... ឃ
**ក-ពាក្យថា សោភណចិត្ត**....................................... ១
-ពាក្យថា មហាកុសលចិត្ត..................................... ២
-កាមាវចរសោភណចិត្ត ២៤ ដួង.......................... ៤
-មហាកុសលចិត្ត ៨ ដួងគឺៈ.................................. ៤
-មហាកុសលចិត្តដួងទី ១...................................... ៤
ធម៌អប់រំចិត្ត ស្តីអំពី រៀនធម៌តែមិនដឹងធម៌............. ៦
-មហាកុសលចិត្តទី ២.......................................... ៧
ធម៌អប់រំចិត្ត ស្តីអំពី ការថែរក្សាចិត្ត......................... ៩
មហាកុសលចិត្តដួងទី ៣....................................... ១០
ធម៌អប់រំចិត្ត ស្តីអំពី ចិត្តមានពិត.............................. ១២
មហាកុសលចិត្តដួងទី ៤........................................ ១៣
ធម៌អប់រំចិត្ត ស្តីអំពី ចិត្តកើតរលត់ .......................... ១៥
មហាកុសលចិត្តដួងទី ៥........................................ ១៦
ធម៌អប់រំចិត្ត ស្តីអំពី ចិត្តដោយអត្ថថាប្រមូល............. ១៨
មហាកុសលចិត្តដួងទី ៦........................................ ១៩

ធម៌អប់រំចិត្ត ស្ដីអំពី អ្វីៗកើតអាស្រ័យហេតុ-បច្ច័យ..... ២១
មហាកុសលចិត្តដួងទី ៧........................................ ២២
ធម៌អប់រំចិត្ត ស្ដីអំពី កិលេស ៣ ថ្នាក់........................ ២៤
មហាកុសលចិត្តដួងទី ៨........................................ ២៥
ធម៌អប់រំចិត្ត ស្ដីអំពី ជីវិតគឺវិថីចិត្ត............................ ២៧
**ខ-ពាក្យថា មហាវិបាកចិត្ត**.................................. ២៨
មហាវិបាកចិត្តដួងទី ១.......................................... ២៩
ធម៌អប់រំចិត្ត ស្ដីអំពី ជីវិតរស់នៅក្នុងព្រះធម៌.............. ៣១
មហាវិបាកចិត្តដួង ទី២.......................................... ៣២
ធម៌អប់រំចិត្តស្ដីអំពី វិបស្សនាមិនលំអៀងចំពោះ
អារម្មណ៍......................................................... ៣៤
មហាវិបាកចិត្តដួងទី ៣.......................................... ៣៥
ធម៌អប់រំចិត្ត ស្ដីអំពីការដេកលក់ស៊ប់........................ ៣៧
មហាវិបាកចិត្តដួងទី ៤.......................................... ៣៨
ធម៌អប់រំចិត្ត ស្ដីអំពី ប្រយោជន៍នៃព្រហ្មចរិយៈ............ ៤០
មហាវិបាកចិត្តដួងទី ៥.......................................... ៤១
ធម៌អប់រំចិត្ត ស្ដីអំពី ធម៌នាំឱ្យកើតក្នុងស្ថានសួគ៌.......... ៤៣
មហាវិបាកចិត្តទី ៦.............................................. ៤៤
ធម៌អប់រំចិត្តស្ដីអំពីបុគ្គលអ្នកមានមិច្ឆាទិដ្ឋិរស់នៅចង្អៀត
ដែនដី.............................................................. ៤៦
មហាវិបាលចិត្តដួងទី ៧.......................................... ៤៧

ធម៌អប់រំចិត្ត ស្ដីអំពី មិច្ឆាទិដ្ឋិមានទោសធ្ងន់................ ៤៩
មហាវិបាកចិត្តដួងទី ៨............................................ ៥០
ធម៌អប់រំចិត្ត ស្ដីអំពី មានព្យាយាមនាំមកនូវសុខ.......... ៥២
**គ-ពាក្យថា មហាកិរិយាចិត្ត**..................................... ៥៤
មហាកិរិយាចិត្ត ៨ដួង គឺ......................................... ៥៥
មហាកិរិយាចិត្តដួងទី ១.......................................... ៥៥
ធម៌អប់រំចិត្ត ស្ដីអំពី មិនបានចាក់ធ្លុះធម៌ ៤ យ៉ាង........ ៥៧
មហាកិរិយាដួងទី ២............................................... ៥៨
ធម៌អប់រំចិត្ត ស្ដីអំពី អានិសង្សការចាក់ធ្លុះធម៌ ៤ យ៉ាង. ៦០
មហាកិរិយាចិត្តដួងទី ៣.......................................... ៦១
ធម៌អប់រំចិត្ត ស្ដីអំពី ប្រយោជន៍ព្រះអរិយៈ.................. ៦២
មហាកិរិយាចិត្តដួងទី ៤........................................... ៦៤
ធម៌អប់រំចិត្ត ស្ដីអំពី ព្រះអរហត្តជាធម៌ដ៏ប្រសើរ........... ៦៦
មហាកិរិយាចិត្តដួងទី ៥........................................... ៦៧
ធម៌អប់រំចិត្តស្ដីអំពី ការកោតក្រែងរបស់ព្រះខីណាស្រព ៦៩
មហាកិរិយាចិត្តដួងទី ៦.......................................... ៧០
ធម៌អប់រំចិត្ត ស្ដីអំពី ប្រយោជន៍ព្រហ្មចរិយៈ................ ៧២
មហាកិរិយាចិត្តដួងទី ៧.......................................... ៧៣
ធម៌អប់រំចិត្ត ស្ដីអំពី កាយគតាសតិ.......................... ៧៤
មហាកិរិយាចិត្តដួងទី ៨........................................... ៧៥
ធម៌អប់រំចិត្ត ស្ដីអំពី បរិស័ទស្រកេកស្រកាក និងផូរផង់. ៧៧

**ឃ-អធិប្បាយបន្ថែមមហាកុសលចិត្ត ៨ ដួង**.......... ៧៨
**ខ-វិធីរាប់កុសលចិត្តដោយពិស្តារ**......................... ៨១
ហេតុ-បច្ច័យនៃធម៌ផ្សេងៗ...................................... ៨២
ហេតុឱ្យកើតកុសលសោមនស្ស ៦ យ៉ាង.................. ៨២
ហេតុឱ្យកើតកុសលឧបេក្ខា ៦ យ៉ាង........................ ៨៣
ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៤ (ន័យទី ១).... ៨៣
ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៧ (ន័យទី ២)... ៨៣
ហេតុឲ្យកើតកុលសញាណវិប្បយុត្ត ៤ (ន័យទី ១)...... ៨៤
ហេតុឱ្យកើតកុសលញាណវិប្បយុត្ត ៧ (ន័យទី ២)...... ៨៥
ហេតុឱ្យកើតអសង្ខារិកចិត្ត ៦ យ៉ាងគឺ....................... ៨៥
ចែកកុសលដោយឧក្កដ្ឋៈ និងឱមកជា ៤................... ៨៦
ចែកកុសលដោយឧក្កដ្ឋ និង ឱមក ៨....................... ៨៦
**ច-អធិប្បាយបន្ថែមមហាវិបាកចិត្ត ៨ ដួង**........... ៨៧
ផល ២ យ៉ាង........................................................ ៨៨
មហាវិបាកផ្សេងពីមហាកុសល................................ ៨៩
ស្ថានដែលឱ្យផលរបស់មហាវិបាក ៨ មាន ៤ ស្ថាន.... ៩០
មហាវិបាកចែកសត្វឱ្យផ្សេងគ្នា................................ ៩១
**ខ-អធិប្បាយបន្ថែមមហាកិរិយាចិត្ត ៨ ដួង**........... ៩៣

# ពាក្យថា សោភណចិត្ត

**សោភណចិត្ត** មកពី (សោភណ + ចិត្ត) ប្រែថា ចិត្តល្អស្អាត ។ ព្រោះចិត្តនេះ មិនបានកើតរួមជាមួយ អកុសលចេតសិកឡើយ ចិត្តណាដែលប្រកបជាមួយ អកុសលចេតសិក ចិត្តនោះឈ្មោះថា អកុសលចិត្ត ឬ អសោភណចិត្ត ។ ចំណែកឯចិត្តទាំងឡាយណា ដែល ប្រកបជាមួយ សោភណចេតសិក ចិត្តនោះឈ្មោះថា សោភណចិត្ត ។

ក្នុងសេចក្តីនេះ ព្រះអនុរុទ្ធាចារ្យលោកមិនបានពោល ដល់អសោភណចិត្តឡើយ ក្នុងចិត្ត៨៩ដួង មានចំនួន៥៩ ដួង ជាសោភណចិត្ត ចិត្តក្រៅពីនេះជា អសោភណចិត្ត ទាំងអស់ ។ ដូចបាលីពោល ក្នុងគម្ពីរអភិធម្មត្ថសង្គហ ថា:

**បាបាហេតុកមុត្តានិ សោភណានីតិ វុច្ចរេ**
**ឯកូនសដ្ឋី ចិត្តានិ អថេកនវុតីបិ វា**

ប្រែថា: វៀរចិត្តអកុសល និងអហេតុកហើយចំនួន ចិត្ត ៥៩ ដួង ហៅថាសោភណចិត្ត ឬ ចិត្តចំនួន ៩១ ដួង ជាសោភណចិត្ត ។

# ចងចាំរបស់សោភណចិត្ត ៤ ន័យ

ន័យទី ១ ចិត្តជាកាមាវចរសោភណ ២៤ដួង
ន័យទី ២ ចិត្តជារូបាវចរ ១៥ដួង
ន័យទី ៣ ចិត្តជាអរូបាវចរ ១២ដួង
ន័យទី ៤ ចិត្តជាលោកុត្តរ ៨ដួង ឬ ៤០ដួង

# ពាក្យថា មហាកុសលចិត្ត

**មហាកុសលចិត្ត** មកពី (មហា + កុសល + ចិត្ត ) ឬហៅម៉្យាងទៀតថា កាមាវចរកុសល ។ ថ្វីត្បិតតែជាកុសលមែន ប៉ុន្តែមិនមែនមានតែកាមាវចរកុសលទេ គឺចែកទៅតាមភូមិផ្សេងៗ កុសលដែលនៅក្នុងកាមភូមិហៅថា កាមាវចរកុសល កុសលដែលនៅក្នុងរូបភូមិហៅថា រូបាវចរកុសល កុសលដែលនៅក្នុងអរូបាវចរភូមិ

ហៅថា អរូបាវចរកុសល កុសលដែលនៅក្នុងលោកុត្តរភូមិ ហៅថា លោកុត្តរកុសល ។ កាមាវចរកុសលនេះ យើងហៅម៉្យាងទៀតថា មហាកុសល ព្រោះមហាកុសលនេះ មានអំណាចខ្លាំង អាចដើម្បីផ្សាយទៅបានច្រើនភូមិ ដែលខុសប្លែកពីចិត្តដទៃ ចិត្តក្រៅពីមហាកុសលមិនអាចផ្សាយទៅគ្រប់ភូមិបានទេ ព្រោះហេតុដូច្នេះ បានជាលោកពោលហៅកាមាវចរកុសលនេះថា ជាមហាកុសល ។ មហា-កុសលនេះ គឺមានកិច្ចតួនាទីរបស់ខ្លួនក្នុងការលះបង់នូវបាបធម៌ផ្សេងៗ ។

# ភាមាវចរសោភណចិត្ត ២៤ ដួង
# មហាកុសលចិត្ត ៨ ដួងគឺៈ

## មហាកុសលចិត្តដួងទី ១

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រកបដោយបញ្ញាមានកម្លាំងខ្លាំងក្លាឥតមានអ្នកដទៃបបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៨

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២៥ ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៦ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៨ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៨ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៨ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

ការដែលធ្វើឱ្យអ្នកដទៃដល់នូវសេចក្តីទុក្ខ មិនខុសអ្វីពីការដែលសាងទុក្ខឱ្យដល់ខ្លួនឯងឡើយ ព្រោះនេះជាបាបកម្មពៀរវេរា ។

( *សាងសុខប្រសើរជាងសាងទុក្ខ* )

# ធម៌អប់រំចិត្ត

## *ស្តីអំពី រៀនធម៌ តែមិនដឹងធម៌*

ពាក្យថាធម៌ក្នុងទីនេះ គឺសំដៅដល់ធម្មជាតិ ធម្មជាតិ គឺអ្វីៗដែលកើតឡើងដោយសារហេតុ និងបច្ច័យ ។ មនុស្ស យើងកាលបើសិក្សាវិជ្ជាអ្វីមួយហើយ តែងតែចង់ដឹងស្វែង យល់អំពីអ្វីដែលខ្លួនសិក្សារៀននោះ ។ ប៉ុន្តែបន្ទាប់ពីការ រៀនសូត្ររួចហើយ អ្វីដែលមិនធ្លាប់ឃើញក៏ឃើញទៅតាម ការដែលបានសិក្សារួចមែន ។ ក៏ប៉ុន្តែ ការដែលសិក្សា នោះ គឺសិក្សាពីរបស់ពិតក្នុងរបស់ដែលមិនពិត ម្លោះហើយ ការចេះដឹង ក៏ចេះដឹងក្នុងរបស់មិនពិត ដល់ទៅរបស់ ពិតវាកើតឡើង បញ្ចេញលក្ខណៈឱ្យឃើញច្បាស់ស្រាប់ តែប្រទូស្តចំពោះរបស់ពិតនោះ ឧទាហរណ៍ ពេលម៉ែខឹង នឹងកូនហើយ ក៏ឈ្លោះប្រកែកជាមួយនឹងកូន ឬក៏អាច វាយកូនថែមទៀត នេះគឺមកពីអ្វី គឺមកពីម៉ែហ្នឹងយល់ ឃើញថា មានកូនទៅតាមសេចក្តីពិតមែន ។ តែតាម ពិតខ្លួនឯងអ្នកខឹងក៏មិនមាន ទៅតាមពិតនៃបរមត្ថ ឯអ្នក ដែលត្រូវខឹងជាមួយនោះ ក៏មិនមានពិតដោយ បរមត្ថ

ដែរ ។ ចំពោះខ្លួនឯង ឬអ្នកដទៃ វាជាការពិតដែរ តែពិតដោយការសន្មតិប៉ុណ្ណោះ ក្នុងបរមត្ថពុំមានខ្លួនឯង ពុំមានអ្នកដទៃឡើយ ឯពិតមែនទែននោះ គឺរូបធម៌និងនាមធម៌ដែលកើតឡើងដោយប្រាសចាកសត្វ បុគ្គល និងតួខ្លួនទាំងអស់ ។

## មហាកុសលចិត្តដួងទី ២

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃបបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៨

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២៥ ។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៦ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៨ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៨ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៨ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

មនុស្សទាំងអស់គ្រប់ៗគ្នា មិនអាចរំពឹងសង្ឃឹមចំពោះរបស់អ្វីៗក្នុងលោកនេះបានឡើយ ដោយហោចទៅ សូម្បីតែខ្លួនឯងក៏មិនមានទៅតាមសេចក្តីពិតផង ។

# ធម៌អប់រំចិត្ត

## ស្តីអំពី ការថែរក្សាចិត្ត

រូបអាស្រ័យចិត្ត ទើបហៅថា មនុស្សសត្វ មហាភូតរូបទាំង ៤ អាស្រ័យចិត្តទើបមានចលនា។ គ្រប់ឥរិយាបថទាំងបួនដូចជា៖ ការដេក ដើរ ឈរ អង្គុយ បើមិនមានចិត្តជាទីអាស្រ័យទេ ក៏មិនអាច ប្រព្រឹត្តទៅបានដែរ ។

ចិត្តជានាមធម៌ម្យ៉ាងផ្សេងពីនាមធម៌ដទៃ មានសេចក្តីថា ចិត្តនេះអាចទទួលរ៉ាប់រងនូវអារម្មណ៍របស់ចិត្ត និងចិត្តដែលប៉ះខ្ទប់គ្នា ។ ប៉ុន្តែ ដែលគួរឱ្យប្រយ័ត្ន គឺពេលដែលចិត្តប៉ះខ្ទប់នឹងអារម្មរណ៍មិនល្អ ឧទាហរណ៍ ចិត្តឃើញកើតឡើង បានឃើញនូវរូបមិនល្អដូចជា សាកសពរបស់មនុស្សស្លាប់ ឆ្កែស្លាប់ កណ្តុរស្លាប់ រួចទៅចក្ខុទ្វារវិថីកន្លងផុតទៅ អារម្មណ៍នេះក៏បញ្ជូលទៅឱ្យមនោទ្វារវិថីពេលនោះចិត្តខឹងក៏កើតឡើង ។ ព្រោះតែមិនបានពិចារណានូវវិបាកដែលកើតឡើង អាស្រ័យកម្មជាបច្ច័យដូចជាឃើញរូបមិនល្អ នេះជាអកុសលវិបាក ដែលអាស្រ័យអកុសលកម្មជាបច្ច័យ ។ ការដែលថែរក្សាចិត្តទៅបាន

ទាល់តែពិចារណាហេតុផលយ៉ាងនេះ ហើយក៏បានទទួលព្រមទៅតាមការពិត ដែលកើតដោយសេចក្តីថា អ្វីៗកើតពីហេតុ ។

## មហាកុសលចិត្តដួងទី ៣

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា ឥតមានអ្នកដទៃបបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៧

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២៤ (វៀរបញ្ញាចេតសិក) ។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៥ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

### ចែកជាធាតុ

-ចេតសិក ៣៧ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៧ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៧ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ម្នាលអ្នកទាំងឡាយ អ្នកគប្បីធ្វើសេចក្តីល្អ ព្រោះថាសេចក្តីល្អ រមែងនាំមកនូវសេចក្តីសុខ រីឯតថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវតែប៉ុណ្ណោះ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី ចិត្តមានពិត*

ចិត្តមានពិត តើចិត្តស្ថិតនៅទីណា ? ចិត្តគ្មានស្ថិតក្នុងទីណាទេ តែចិត្តមានហទយវត្ថុជាទីអាស្រ័យ ហើយចិត្តជាសភាវធម៌ដែលជាខាងក្នុង ។ ឧទាហរណ៍ ក្នុងខណៈឃើញរូប ចិត្តមិនបាននៅខាងក្រៅទេ ចំពោះវណ្ណរូបដែលកំពុងប្រាកដគឺ ជារបស់ខាងក្រៅ។ ចិត្តជាសភាវធម៌ដែលនៅខាងក្នុង គឺជាសភាវធម៌ដែលកំពុងដឹងសភាវៈរូបារម្មណ៍ ដែលកំពុងប្រាកដតាមផ្លូវភ្នែក ។

ការអប់រំចម្រើនបញ្ញា គឺត្រូវដឹងលក្ខណៈនៃសភាវធម៌ត្រង់តាមសេចក្តីពិត ដែលព្រះដ៏មានព្រះភាគសម្តែងពីការចម្រើននូវចិត្តានុបស្សនាសតិប្បដ្ឋាន គឺខណៈណាដែលឃើញហើយរឭកបានមិនវង្វេងភ្លេច ។ នឹងត្រូវពិចារ-ណាសិក្សាសង្កេតបង្អោនទៅ ដឹងសភាវៈកំពុងប្រាកដ ។ ប៉ុន្តែពេលដឹងថា ចិត្តកំពុងឃើញ ចិត្តកំពុងឮ ចិត្តកំពុងនឹកគិតជាដើម សតិប្បដ្ឋានក៏រមែងកើតឡើង រឭកដឹងនូវលក្ខណៈនៃចិត្ត ដែលជាសភាពដឹងជាធាតុដឹងក្នុងខណៈនោះបាន ។

ដូច្នេះ ការអប់រំចម្រើនបញ្ញា ទើបអាចដឹងលក្ខណៈនៃសភាវធម៌ទៅបាន បើមិនយ៉ាងនេះទេ មិនអាចដឹងនូវសភាវធម៌បានឡើយ ។

## មហាកុសលចិត្តដួងទី ៤

**៤- សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃបបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៧

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២៤ (វៀរបញ្ញាចេតសិក)។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៥ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

### ចែកជាធាតុ

-ចេតសិក ៣៧ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៧ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៧ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

ពន្លឺនៃព្រះអាទិត្យ មិនមានអំណាចដោយខ្លួនឯងឡើយ បើពន្លឺវាមានជាខ្លួនវាមែននោះ ទោះបីអត់ព្រះអាទិត្យក៏វានៅតែភ្លឺដែរ យ៉ាងណាខន្ធនេះក៏ដូចគ្នា ។

# ធម៌អប់រំចិត្ត

*ស្តីអំពី ចិត្តកើតរលត់*

ចិត្តជាសភាវៈមិនឋិតនៅបានយូរ កើតឡើងហើយក៏រលត់ទៅភ្លាម រួចចិត្តក្រោយក៏រមែងកើតឡើងទៀត ។ ការរលត់ទៅនៃចិត្តដួងខណៈមុន ជាបច្ច័យឱ្យចិត្តដួងខណៈបន្ទាប់កើតឡើង ។ ពេលដែលចិត្តឃើញកើតឡើងហើយចិត្តឃើញនេះ មិនអាចនៅតែឃើញរហូតបានទេ គឺត្រូវតែរលត់ទៅទើបចិត្តថ្មីកើតជាបន្ត ។

ក្នុងខណៈដែលកំពុងដេកលក់យ៉ាងស៊ប់ មិនយល់សប្តិ ចិត្តកើតរលត់បន្តគ្នារឿយៗ តែមិនដឹងអារម្មណ៍ផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តបានឡើយ ។ ចិត្តទាំងឡាយណា ដែលមិនដឹងអារម្មណ៍តាម ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ចិត្តនោះ ឈ្មោះថា ភវង្គចិត្តគឺតម្រងរក្សាភពរបស់បុគ្គលអ្នកដេកលក់យ៉ាងស៊ប់នោះ បន្តទុករហូតដល់ចិត្តដទៃកើតឡើង ។ ដូច្នេះ ការប្រព្រឹត្តិទៅនៃជីវិតនោះ បើដេកលក់ក៏ដោយ មិនដេកលក់ក៏ដោយ គឺជាការប្រព្រឹត្តិ

ដែលតែងតែប្រកាន់ចំពោះចិត្តនេះថា ជាតួខ្លួនយើង។ សេចក្ដីនេះ ទាល់តែបានអប់រំបញ្ញាជារឿយៗ ប្រក្រតីនូវក្នុងជីវិតប្រចាំថ្ងៃ ។

## មហាកុសលចិត្តដួងទី ៥

**៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លាឥតមានអ្នកដទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៧

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-សោភណចេតសិក ២៥ ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៥ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៧ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៧ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៧ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-មនុស្សយើងគួរតែសាងសេចក្តីមេត្តាករុណា ឱ្យបានច្រើន ប្រសើរជាងសាងកំហឹង គំនុំ ព្យាបាទ ។

-មនុស្សសើច មិនប្រាកដថារីករាយបានទេ ។

(*សាងល្អ ឈ្មោះថាសាងសេចក្តីសុខឱ្យដល់ខ្លួនឯង*)

# ធម៌អប់រំចិត្ត

## *ស្ដីអំពី ចិត្តដោយអត្ថថាប្រមូល*

ពេលណាដែលចិត្តកើតឡើង ប៉ះខ្ទប់ជាមួយអារម្មណ៍ និងពេលដែលអារម្មណ៍នោះ កន្លងបញ្ចទ្វារចូលមកដល់មនោទ្វារ។ ត្រង់ជវនកិច្ចកើតឡើង ចំណុចនេះអាចនិយាយបានថាជាការប្រព្រឹត្តិទៅនៃចិត្ត ដោយអត្ថថាប្រមូល ព្រោះថាកុសលក្ដី អកុសលក្ដី កើតត្រង់ចិត្តធ្វើជវនកិច្ច នេះឯង ។

ដូច្នេះ អ្វីដែលបានប៉ះខ្ទប់រវាងអារម្មណ៍ និងចិត្តជាអនន្តរូបនិស្សយប្បច្ច័យ ដែលបានកើតបន្តបន្ទាប់គ្នា រហូតមកដល់ជវនកិច្ចនេះ គឺបានសម្រេចជាកម្ម បើបានសម្រេចជាកម្មហើយ តែងតែញុំាងនូវវិបាកឱ្យកើតវិបាកគ្រប់យ៉ាងដូចជាវិបាកដែលត្រូវឱ្យផល ក្នុងបដិសន្ធិកាលក្ដី វិបាកដែលត្រូវឱ្យផលក្នុងបវត្តិកាលក្ដី គឺសុទ្ធតែជាផលនៃអំពើកម្មទាំងអស់ ។

វដ្តសង្សារដែលនៅតែវែង ព្រោះតែសត្វលោកប្រមូលកម្មស្រឡាញ់កម្ម ។ សូម្បីតែប្រព្រឹត្តទៅក្នុងវដ្តកុសលប្រព្រឹត្តទៅដើម្បីភពជាតិកំណើត ។ ម្ល៉ោះហើយអ្វីៗគ្រប់

យ៉ាងដែលបានធ្វើ ដែលកំពុងធ្វើដើម្បីជាយ៉ាងនេះ ដើម្បីជាយ៉ាងនោះ មិនមែនប្រព្រឹត្តទៅដើម្បីកាត់ផ្តាច់នូវវដ្តៈទេ។

## មហាកុសលចិត្តដួងទី ៦

**៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៧

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក)

-សោភណចេតសិក ២៥ ។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៥ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ

## ចែកជាធាតុ

-ចេតសិក ៣៧ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៧ ជាធម្មាយតន

-មហាកុសលចិត្ត មនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៧ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-មនុស្សយើងគួរដឹងថា អ្នកដែលប្រាប់ពីទោសកំហុសដល់ខ្លួន ប្រៀបដូចជាប្រាប់នូវកំណាប់ទ្រព្យ ដល់យើងអ៊ីចឹង ។

-មនុស្សយើងគ្រប់គ្នា មិនអាចក្រឡេកមើលនូវអ្វីៗជុំវិញខ្លួន ឲ្យសព្វគ្រប់បានឡើយ ។

# ធម៌អប់រំចិត្ត

## *ស្ដីអំពី អ្វីៗកើតអាស្រ័យហេតុ-បច្ច័យ*

ការជវនវិថីចិត្តកើតរលត់ សោយនូវអារម្មណ៍ដដែលៗដល់ ៧ ខណៈនោះប្រព្រឹត្តទៅដោយអំណាចនៃបច្ច័យគឺជវនវិថីចិត្តខណៈទី១ ជាអាសេវនប្បច្ច័យ[1] ឲ្យជវនវិថីចិត្តខណៈទី២កើតឡើង សោយអារម្មណ៍នោះដដែល ៗ ទៀត សូម្បីជវនវិថីចិត្តខណៈទី២ ក៏ជាអាសេវនប្បច្ច័យឲ្យជវនវិថីចិត្តទី ៣ កើតឡើងសោយអារម្មណ៍នោះដដែលទៀត រហូតរឿយៗ ទៅដល់ជវនវិថីចិត្តទី៧ ទើបមិនអាចជាអាសេវនប្បច្ច័យ ។

ព្រោះហេតុដូច្នេះ ទើបជាកម្លាំងធ្វើឱ្យកុសលចិត្ត និងអកុសលចិត្ត ជាកម្មប្បច្ច័យឱ្យវិបាកចិត្ត ដែលជាផលកើតឡើងក្នុងអនាគត និងជាឧបនិស្សយប្បច្ច័យឲ្យកុសល

(1) *អាសេវនប្បច្ច័យ គឺអកុសលជវនវិថីចិត្ត កុសលជវនវិថីចិត្ត ឬកិរិយាជវនវិថីចិត្ត ដែលធ្វើឲ្យចិត្តមានជាតិតែ ១ ដូចគ្នា កើតឡើងធ្វើជវនកិច្ចដដែលៗទៀត ។*

ជវនវិថី និងអកុសលជវនវិថី កើតឡើងទៀត ក្នុងអនាគត។ ការសិក្សាយ៉ាងនេះ គឺដើម្បីឃើញថាអ្វីៗ កើតឡើងព្រោះហេតុ និងបច្ច័យ ដោយកម្ចាត់បង់នូវទិដ្ឋិ ដែលតែងតែយល់ថាតួខ្លួន សត្វបុគ្គល បុរស ស្ត្រី គ្រហស្ថ បព្វជិត ។

## មហាកុសលចិត្តដួងទី ៧

**៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លាឥតមានអ្នកដទៃបបួលដឹកនាំ។

## មានចេតសិកប្រកប ៣៦

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក )

-សោភណចេតសិក ២៤ (វៀរបញ្ញាចេតសិក ) ។

## ចែកជាខន្ធ

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៣៤ | ជាសង្ខារក្ខន្ធ |
| -មហាកុសលចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

## ចែកជាធាតុ

-ចេតសិក ៣៦ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៦ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៦ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

*-អ្នកទាំងឡាយមានឆ្ងល់ដែរទេថា បើព្រះសម្មាសម្ពុទ្ធដែលបានត្រាស់ក្នុងលោកមានច្រើនព្រះអង្គ អម្បាលដូចដីខ្សាច់យ៉ាងនេះ ចុះហេតុអ្វីក៏នៅតែមានវដ្តសង្សារទៀត ។*

# ធម៌អប់រំចិត្ត

## *ស្តីអំពី កិលេស ៣ ថ្នាក់*

ចំពោះការសន្សំ អកុសលប្រភេទផ្សេងៗ ច្រើនសន្ទឹកសន្ទាប់ ពេលដែលបើកភ្នែកភ្ញាក់ឡើង ឃើញរូបហើយក៏ធ្វើឱ្យវង្វេងភ្លាម ។

ខណៈដែលភវង្គចិត្តនោះ មិនដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក អណ្តាត កាយ ចិត្តទេ ។ ព្រោះបើនឹកគិត ឬយល់សប្តិ ក៏ជាមនោទ្វារវិថីចិត្តដែរ មិនមែនជាភវង្គចិត្ត ។ ដូច្នេះគ្រប់ពេលដែលភវង្គចិត្តនោះកើតឡើង ខណៈនោះមិនបានដឹងនូវអារម្មណ៍ក៏ដោយ ក៏ពេលនោះមាននូវអនុសយកិលេសដែរ ។ ព្រោះកិលេស មាន ៣ ថ្នាក់គឺ ៖

-អនុសយកិលេស ជាកិលេសយ៉ាងល្អិត ដែលសន្សំដេកពួនសម្ងំនៅក្នុងចិត្ត ។

-បរិយុដ្ឋានកិលេស ជាកិលេសយ៉ាងកណ្តាល ដែលកើតរួមនឹងជវនវិថីចិត្ត ។

-វីតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ដែលកើតរួមនឹងជវនវិថីចិត្ត ។

-សេចក្តីនេះ សូម្បីចិត្តដែលមិនមែនជា ជវនវិថីចិត្ត ក៏មានអនុសយកិលេសដែរ វៀរលែងតែចិត្តរបស់ព្រះអរហន្តប៉ុណ្ណោះ ដែលមិនមានកិលេសណាៗទាំងអស់ ។

## មហាកុសលចិត្តដួងទី ៨

**៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងទន់ ខ្សោយ អាស្រ័យអ្នកដទៃបបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៦

-អញ្ញសមានាចេតសិក១២ ( វៀរ បីតិ )

-សោភណចេតសិក ២៤ (វៀរ បញ្ញាចេតសិក )។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៤ ជាសង្ខារក្ខន្ធ

-មហាកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៦ ជាធម្មធាតុ

-មហាកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៦ ជាធម្មាយតន

-មហាកុសលចិត្ត ជាមនាយតន

## ចែកជាសច្ច

-ចេតសិក ៣៦ ជាទុក្ខសច្ច

-មហាកុសលចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-ធម្មជាតិនៃស្ករ តែងតែរក្សានូវរសផ្អែម ទោះបីនៅទីកន្លែងណា ឬនៅហ្នឹងអ្វីក៏ដោយ ។

-ស្ករនៅនឹងម្សៅធ្វើនំ ទៅជានំផ្អែម ។

-យកស្ករបបរជាមួយសណ្តែក ទៅជាបបរសណ្តែកផ្អែម ។

# ធម៌អប់រំចិត្ត

## *ស្ដីអំពី ជីវិតគឺវិថីចិត្ត*

ខណៈណា ដែលវិថីចិត្តកើតឡើង ឃើញសភាវៈដែលប្រាកដតាមភ្នែក ឮសម្លេងដែលប្រាកដតាមត្រចៀក ធុំក្លិនតាមច្រមុះ ទទួលរស់តាមអណ្ដាតប៉ះខ្ទប់សម្ផស្សផោ-ដ្ឋព្វៈតាមកាយ ឬ នឹកគិតរឿងរ៉ាវផ្សេងៗតាមចិត្ត ។

ខណៈនោះ ជាជវនវិថីចិត្តក៏សន្សំសន្តាននៃខ្លួនកើតឡើងទាំងអស់ ជាកាមាវចរកុសល និងអកុសល និងកាមាវចរកិរិយាជវនវិថី ។

-ខណៈដែលកំពុងឃើញរូបវិថីចិត្តទាំង ៧ វិថី ជាចក្ខុទ្វារវិថី ។

-ខណៈដែលកំពុងឮសម្លេង វិថីចិត្តទាំង ៧ វិថី ជាសោតទ្វារវិថី ។

-ខណៈដែលកំពុងធុំក្លិន វិថីចិត្តទាំង ៧ វិថីជា ឃាន-ទ្វារវិថី ។

-ខណៈដែលកំពុងទទួលដឹងរស់ វិថីចិត្តទាំង ៧ វិថីជាជីវ្ហាទ្វារវិថី ។

-ខណៈដែលកំពុងដឹងផោដ្ឋព្វៈ វិថីចិត្តទាំង៧ វិថីជា
កាយទ្វារវិថី ។

-ខណៈដែលកំពុងនឹកគិត វិថីចិត្តទាំង ៣ វិថីជា
មនោទ្វារវិថី ។

សេចក្តីនេះ ជាវិថីនៃជីវិត ជីវិតគឺជាវិថីចិត្ត ដែលកំពុងឋិតនៅ ដែលផ្ទុយពីការសន្មតិ ។

## ពាក្យថា មហាវិបាកចិត្ត

**មហាវិបាកចិត្ត** មកពី មហា+វិបាក+ចិត្ត មានសេចក្តីថា ចិត្តជាផលនៃកម្មដែលកម្មនេះ បានកសាងហើយ ។ កាមាវចរកុសលចិត្ត ៨ ដួង កើតឡើង សម្រេចជាកុសលកម្មហើយ ចេតនាដែលធ្វើកុសលកម្មនោះៗ ជាកម្មប្បច្ច័យ ឱ្យកាមាវចរកុសលវិបាក ១៦ ដួងកើតឡើង ជាផលរបស់កម្មនោះៗ តាមសមគួរដល់ហេតុ និងកាល ។

កាមាវចរកុសលវិបាកចិត្ត ១៦ ដួង គឺអហេតុកកុសលវិបាក ៨ ដួង និងកាមាវចរសហេតុកកុសលវិបាក (មហាវិបាក ៨ ដួង) ។ មហាវិបាកចិត្តដួងនេះ មានសោភណចេតសិកកើតរួមជាមួយផង ទើបមានឈ្មោះថា សហេតុកកុសលវិបាកចិត្ត ខុសពីអហេតុកកុសល-វិបាកចិត្ត ៨ ដួង ដែលមិនមានសោភណចេតសិកកើតរួមជាមួយ ។

# មហាវិបាកចិត្ត៨ ដួងគឺ

*មហាវិបាកចិត្តដួងទី ១*

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រកបព្រមដោយបញ្ញា មានកម្លាំងខ្លាំងក្លា មិនបានអាស្រ័យអ្នកដទៃបបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៣

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក២០ (វៀរវិរតិ ៣ និងអប្បមញ្ញា ២) ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៣ ជាធម្មធាតុ

-មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៣ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៣ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-មនុស្សយើងមិនអាចរស់ មិនអាចស្លាប់នៅពេលតែមួយបានទេ គឺត្រូវតែចែកពេលគ្នា ក៏ប៉ុន្តែសេចក្ដីទុក្ខតែងតែនៅជាមួយមនុស្សលោកគ្រប់គ្នា ហើយគ្រប់ពេលទៀតផង ។

# ធម៌អប់រំចិត្ត

## ស្តីអំពី ជីវិតរស់នៅក្នុងព្រះធម៌

ជីវិតដែលបានរស់នៅក្នុងព្រះធម៌ រមែងរួចផុតចាកកង្វល់ ។ អារម្មណ៍ជាគ្រឿងផ្សំរបស់ចិត្ត នាំឱ្យចិត្តរវល់ ភាពរវល់របស់ចិត្ត ធ្វើឱ្យចិត្តសាំញ៉ាំ មិនជ្រះស្រឡះ ។ ប៉ុន្តែកាលបើបានទទួលពាក្យពន្យល់ពីព្រះធម៌ រមែងមិនកង្វល់ចំពោះអារម្មណ៍ ព្រះធម៌បានពន្យល់ថា ៖

-ធម្មតាអារម្មណ៍ តែងតែប៉ះខ្ទប់ជាមួយចិត្ត ។

-ធម្មតាអារម្មណ៍ មានទាំងល្អ មានទាំងអាក្រក់ ។

-ធម្មតានៃទឹកសមុទ្រ តែងតែមានរសជាតិប្រៃ ។

-ធម្មតានៃភ្លើងតែងតែក្តៅ ។

កាលបើយល់ពីពាក្យថា ធម្មតាហើយវាគ្មានរឿងអ្វីដែលធ្វើឱ្យយើងមិនសុខចិត្តទេ ចំពោះអារម្មណ៍ទាំងពួងនោះ។ ហេតុដែលនាំឱ្យកើតទុក្ខ ហេតុដែលមិនសុខចិត្ត ហេតុដែលកង្វល់ មកពីចិត្តតែងតែញាប់ញ័រចំពោះអារម្មណ៍ ។

កាលបើចិត្តមិនប្រកាន់ ចាប់យកនូវអារម្មណ៍ថា ជារបស់ខ្លួនហើយ គ្មានរឿងអ្វីដែលនាំឱ្យកើតទុក្ខឡើយ គឺធ្វើឱ្យចិត្តយល់ព្រមទៅតាមធម្មតា មិនមែនយល់ព្រមចំពោះតែអារម្មណ៍ណាដែលល្អៗនោះទេ ព្រោះថាធម្មតានៃចិត្តតែងតែទទួលគ្រប់អារម្មណ៍ទាំងអស់ ទោះអារម្មណ៍នោះល្អក៏ដោយ មិនល្អក៏ដោយ ។

## មហាវិបាកចិត្តដួង ទី២

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យ អ្នកដទៃបបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៣

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២០ (វៀរវិរតិ ៣និងអប្បមញ្ញា ២)

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

- សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណខន្ធ

**ចែកជាធាតុ**

-ចេតសិក ៣៣ ជាធម្មធាតុ

-មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

**ចែកជាអាយតន**

-ចេតសិក ៣៣ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

**ចែកជាសច្ច**

-ចេតសិក ៣៣ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី វិបស្សនាមិនលំអៀងចំពោះអារម្មណ៍*

បុគ្គលអ្នកប្រតិបត្តិនូវវិបស្សនា គឺមិនលំអៀងចំពោះអារម្មណ៍ណាមួយទេ ទោះអារម្មណ៍នោះ ជាឥដ្ឋារម្មណ៍ ក្តី អារម្មណ៍នោះជាអនិដ្ឋារម្មណ៍ក្តី ។ គឺបានយល់នូវអារម្មណ៍ ប្រាកដច្បាស់ថាជាហេតុ ហើយក៏ជាផលរបស់ចិត្តមុន ។

រូបល្អក្តី រូបមិនល្អក្តី ក៏ជាអារម្មណ៍របស់វិបស្សនាបានដូចគ្នា មិនមែនចាំបាច់តែ រូបស្អាតបានអប់រំចិត្តបាន ដល់មិនស្អាតទាស់ចិត្ត ប្រទូស្តចំពោះរូបខ្លួននោះ មិនមែនយ៉ាងដូច្នេះទេ ។ ដូច្នេះ ពេលដែលចិត្តបានឃើញរូប ឮនូវសម្លេង ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងដឹងនូវរឿងរ៉ាវផ្សេងៗ ។ ក្នុងពេលនេះ ក៏បានដឹងច្បាស់ថាអ្វីៗ ដែលបានកើតទាំងអស់នេះ គ្រាន់តែជាផលរបស់បច្ច័យប៉ុណ្ណោះ ។

ក្នុងខណៈដែលវិបស្សនាកើតឡើង មិនអាចដើម្បីឃើញចំពោះអារម្មណ៍ ដែលជាបញ្ញត្តិថា ជារបស់ពិតប្រាកដបានឡើយ ។ បញ្ញត្តិគ្រាន់តែជាឈ្មោះ ដែល

បញ្ញត្តិទៅលើបរមត្ថ តែបញ្ញត្តិនេះ មិនមានជាភារៈអ្វីទេ។ ឧទាហរណ៍ ប្ដីខឹងប្រពន្ធ ហើយក៏បានវាយប្រពន្ធដោយដំបង ប្រពន្ធក៏រងរបួសយ៉ាងដំណំ ។ នេះជារឿងដែលជាបញ្ញត្តិទៅលើរូបធម៌ នាមធម៌កើតឡើង ពាក្យប្ដីខឹងប្រពន្ធ គឺចិត្តខឹងអាស្រ័យរូបកើតឡើង ពាក្យថាប្រពន្ធ គឺរូបចិត្តអាស្រ័យគ្នាប៉ុណ្ណោះ ។

## មហាវិបាកចិត្តដួងទី ៣

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា មិនអាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

### មានចេតសិក ៣២ ប្រកប

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ១៩ (វៀរវិរតិ ៣ និងអប្បមញ្ញា ២ បញ្ញា ១)។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

- ចេតសិក ៣០ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣២ ជាធម្មធាតុ

-មហាវិបាកចិត្ត

ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣២ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣២ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## *ស្តីអំពីការដេកលក់ស៊ប់*

ក្នុងខណៈដែលដេកលក់យ៉ាងស៊ប់ មិនមានអារម្មណ៍រឿយៗ ។ នាមខន្ធទាំង ៤ គឺចិត្តនិងចេតសិកត្រូវកើតរួមគ្នា បែកគ្នាមិនបានឡើយ ក្នុងខណៈដែលដេកលក់ស៊ប់វិបាកចិត្ត ជាផលរបស់អតីតកម្ម ទើបធ្វើឱ្យបុគ្គលដែលដេកលក់ស៊ប់នោះនៅមិនស្លាប់ ព្រោះវិបាកចិត្តកើតឡើងបន្តគ្នានៅត្រង់ភពជាតិ កាលបើចិត្តកើតឡើង ក៏ត្រូវមានចេតសិកកើតរួមគ្រប់ពេល ។ វេទនាចេតសិកកើតជាមួយភវង្គចិត្ត គឺមិនមែនជាអារម្មណ៍នៃលោកនេះទើបមិនដឹងខ្លួន ដូចយ៉ាងខណៈដែលចិត្តកំពុងឃើញតាមភ្នែក កំពុងឮតាមត្រចៀកជាដើម មិនមានអ្នកណាអាចដឹងលក្ខណៈនៃវេទនាចេតសិកដែលកើតក្នុងខណៈកំពុងដេកលក់បានឡើយ ។ តែពេលភ្ញាក់ឡើង ក៏គួរនឹងគិតទៀតថា អ្វីភ្ញាក់ ? ពេលគួរគិតទៀតថា អ្វីលក់ ? រូបមិនមែនសភាវៈដឹងទើបរូបមិនភ្ញាក់ មិនលក់ តែនាមធម៌ជាសភាពដឹង កាលបើមិនដឹងអារម្មណ៍ ដែលប្រាកដក្នុង

លោកនេះទើបឈ្មោះថាលក់ តែចិត្តក៏នៅកើតរលត់បន្តតម្រង់ភពជាតិនៅជានិច្ច ទើបមិនស្លាប់ ។

## មហាវិបាកចិត្តដួងទី ៤

**៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

**មានចេតសិក ៣២ ប្រកប**

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ១៩

(វៀរវិរតិ ៣ និងអប្បមញ្ញា ២ បញ្ញា ១ ) ។

**ចែកជាខន្ធ**

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣០ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣២ ជាធម្មធាតុ

-មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣២ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣២ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-ពន្លឺព្រះអាទិត្យអាចបំភ្លឺសត្វលោក បានតែពេលថ្ងៃប៉ុណ្ណោះ ហើយបានចំពោះតែស្រទាប់របស់ធម្មជាតិ រីឯព្រះធម៌វិញ អាចបំភ្លឺបានទាំងថ្ងៃទាំងយប់ ហើយឃើញច្បាស់ចំពោះធម្មជាតិទៀតផង ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី ប្រយោជន៍នៃព្រហ្មចរិយៈ*

( ចាក.បិ.៣៧.ទំ.៥៩ សាវត្ថីនិទាន )

ម្នាលភិក្ខុទាំងឡាយ បើពួកបរិពាជកជាអន្យតិរ្ថិយ សួរពួកអ្នកយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តក្នុងសំណាក់ព្រះសមណគោតម មានប្រយោជន៍អ្វី ? ម្នាលភិក្ខុទាំងឡាយ ពួកអ្នកដែលគេសួរយ៉ាងនេះ ហើយគប្បីដោះស្រាយដល់ពួកបរិពាជកជាអន្យតិរ្ថិយ ទាំនោះយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីលះសញ្ញោជនៈ ។

ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីដកចេញនូវអនុយស័យ។

ម្នាលអ្នកមានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ គប្បីកំណត់ដឹងនូវកាល វែងឆ្ងាយ ។

ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ ព្រះដ៏មានព្រះភាគ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវ វិជ្ជា និង វិមុត្តិ ។

ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីញាណទស្សនៈ ។

ម្នាលអ្នកដ៏មានអាយុ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ ព្រះដ៏មានព្រះភាគ ដើម្បីអនុបាទាបរិនិព្វាន។

## មហាវិបាកចិត្តដួងទី ៥

**៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញាមានកម្លាំងខ្លាំងក្លា មិនបានអាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣២

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក )

-សោភណចេតសិក ២០

(វៀរវិរតិ ៣ និងអប្បមញ្ញា ២) ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣០ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣២ ជាធម្មធាតុ

-មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣២ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣២ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី ធម៌នាំឱ្យកើតក្នុងស្ថានសួគ៌*

( ចាក.បិ.លេខ ៤០.ទំ.៧២ )

**នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យេនេវំ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ យថយិទំ ភិក្ខវេ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។**

ប្រែថា:ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌ដែលជាហេតុនាំពួកសត្វ ដែលបែកធ្លាយរាងកាយស្លាប់ទៅ ឱ្យទៅកើតក្នុងសុគតិសួគ៌ទេវលោក ដូចយ៉ាងសម្មាទិដ្ឋិនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វប្រកបដោយសម្មាទិដ្ឋិ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ។

** ស្ថានសួគ៌ ជាឋានដែលកសាងធ្វើដោយខ្លួនឯង ម៉ែបង្កើតបានតែរូបកាយប៉ុណ្ណោះ មិនអាចធ្វើស្ថានសួគ៌ឲ្យកូនកើតបានឡើយ ។*

# មហាវិបាកចិត្តទី ៦

**៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣២

-អញ្ញសមានាចេតសិក ១២ ( វៀរបីតិចេតសិក )

-សោភណចេតសិក ២០

(វៀរវិរតិចេតសិក ៣ អប្បមញ្ញា ២) ។

## ចែកជាខន្ធ

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៣០ | ជាសង្ខារក្ខន្ធ |
| -មហាវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

## ចែកជាធាតុ

| | |
|---|---|
| -ចេតសិក ៣២ | ជាធម្មធាតុ |
| -មហាវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

## ចែកជាអាយតន

-ចេតសិក ៣២ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣២ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-ព្រះធម៌គឺជាធម្មជាតិដែលមានពិត មិនអាចហួសវិស័យរបស់បុគ្គលអ្នកមានបញ្ញាបានឡើយ ពេលណាដែលបញ្ញាបានឃើញច្បាស់ចំពោះធម្មជាតិ ហើយចិត្តរមែងស្ងប់ចំពោះអារម្មណ៍ដែលបានកើតឡើង ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី បុគ្គលអ្នកមានមិច្ឆាទិដ្ឋិរស់នៅចង្អៀតដែនដី*

( ចាក.បិ.លេខ ៤០.ទំ.៧៥ )

ម្នាលភិក្ខុទាំងឡាយ បុគ្គលមួយកាលកើតឡើងក្នុងលោក ក៏កើតឡើងដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន មិនដើម្បីជាសុខដល់ជនច្រើន ដើម្បីសេចក្តីវិនាសដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំឡាយ បុគ្គលម្នាក់គឺអ្នកណា គឺបុគ្គលជាមិច្ឆាទិដ្ឋិជាអ្នកយល់ខុស បុគ្គលនោះរមែងនាំជនច្រើនឱ្យឃ្លាតចាកព្រះសទ្ធម្មឱ្យតាំងនៅក្នុងអសទ្ធម្ម។

ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់នេះឯង កាលកើតឡើងក្នុងលោក ក៏កើតឡើងដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីវិនាសដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

## មហាវិបាលចិត្តដួងទី ៧

**៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា មិនបានអាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

### មានចេតសិកប្រកប ៣១

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក)

-សោភណចេតសិក ១៩

( វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១ ) ។

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៩ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

### ចែកជាធាតុ

-ចេតសិក ៣១ ជាធម្មធាតុ

- មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

- ចេតសិក ៣១ ជាធម្មាយតន
-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣១ ជាទុក្ខសច្ច
-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

## ✍ ខ្លឹមសារគួរយល់ដឹង

-ព្រះសទ្ធម្មជាដួងប្រទីបបំភ្លឺឱ្យឃើញការពិតនៃធម្មជាតិ ។

-អ្វីដែលផ្ទុយពីធម្មជាតិ សុទ្ធតែជាការក្លែងក្លាយបន្លំទាំងអស់ ។

(*ការឃើញច្បាស់ចំពោះធម្មជាតិនាំមកនូវសេចក្ដីសុខ*)

# **ធម៌អប់រំចិត្ត**

*ស្តីអំពី មិច្ឆាទិដ្ឋិមានទោសធ្ងន់*

( ចាក.បិ.លេខ ៤០.ទំ.៧៦ )

**នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុស្សាមិ យំ ឯវំ មហាសាវជ្ជំ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិបរមានិ ភិក្ខវេ វជ្ជានីតិ ។**

ប្រែថា៖ ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើល មិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលមានទោសធំយ៉ាងនេះ ដូចជាមិច្ឆាទិដ្ឋិនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ។

មិច្ឆាទិដ្ឋិនេះ បុគ្គលណាអាស្រ័យហើយ រមែងខាតបង់នូវប្រយោជន៍ច្រើនយ៉ាង ហើយជាការសោយនូវទុក្ខលំបាក ដ៏ច្រើនក្រៃលែងក្នុងសង្សារវដ្ត ។ ជាការពិតណាស់ កាលណាបុគ្គលពិចារណាឃើញថា មិច្ឆាទិដ្ឋិមានទោសធ្ងន់យ៉ាងនេះ ហើយគប្បីអប់រំចម្រើននូវសម្មា-ទិដ្ឋិឱ្យបានរឿយៗ ប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ កុំឱ្យជីវិតងងឹតសូន្យឱ្យសោះ ព្រោះថាក្រៅអំពីសម្មាទិដ្ឋិ មិនអាចរួចផុតចាកទុក្ខបានឡើយ ។

# មហាវិបាកចិត្តដួងទី ៨

**៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣១

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក)

-សោភណចេតសិក ១៩

( វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១ ) ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៩ ជាសង្ខារក្ខន្ធ

-មហាវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

- ចេតសិក ៣១ ជាធម្មធាតុ

-មហាវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣១ ជាធម្មាយតន

-មហាវិបាកចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣១ ជាទុក្ខសច្ច

-មហាវិបាកចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

-មនុស្សល្អ អ្នកដទៃគេអាចសង្កេតឃើញនិងអាចសន្និដ្ឋានទៅតាមហេតុ ដែលគេបានឃើញនោះ ប៉ុន្តែមនុស្សល្អមិនមែននៅលើអ្នកដទៃគេថានោះឡើយ ។

# ធម៌អប់រំចិត្ត

## *ស្ដីអំពី មានព្យាយាមនាំមកនូវសុខ*

( ចាក.បិ.លេខ ៤០.ទំ.៧៩ )

**ស្វាក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ អារទ្ធវិរិយោ សោ សុខំ វិហរតិ ។ តំ កិស្ស ហេតុ ។ ស្វាក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។ សេយ្យថាបិ ភិក្ខវេ អប្ប-មត្តកោបិ គូថោ ទុគ្គន្ធោ ហោតិ ឯវមេវ ខោ អហំ ភិក្ខវេ អប្បមត្តកំបិ ភវំ ន វណ្ណេមិ អន្តមសោ អច្ឆរា សំឃាតមត្តំបីតិ ។**

ប្រែថា ៖ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្ដា ជាសព្វញ្ញូពោលត្រឹមត្រូវថា បុគ្គលណាមានព្យាយាមបានប្រារព្ធហើយ បុគ្គលនោះតែងនៅជាសុខ ។ ដំណើរនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ដូចលាមកស្អុយមានបន្តិចបន្តួច រមែងមានក្លិនស្អុយយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលសរសើរនូវការបដិសន្ធិក្នុងភពសូម្បីបន្តិចបន្តួច ដោយហោចទៅសូម្បីអស់កាលត្រឹមតែផ្ទាត់ម្រាមដៃម្ដងឡើយ ក៏យ៉ាងនោះឯង ។

*ឆ្លងផុតចាកទុក្ខព្រោះតែសេចក្ដីព្យាយាម*

***<u>ពិចារណា</u>***

សម្មាបដិបទា
(ព្យាយាមក្នុងផ្លូវត្រូវ)

មិច្ឆាបដិបទា
(ព្យាយាមក្នុងផ្លូវខុស)

# ពាក្យថា មហាកិរិយាចិត្ត

**មហាកិរិយាចិត្ត** មកពី មហា+កិរិយា+ចិត្ត មានសេចក្ដីថា ជាអាការៈដែលធំរបស់ការធ្វើ ឬ ជាកុសលប្រភេទមួយ ដែលប្រាសចាកផលសម្រាប់អនាគត បានដល់ការធ្វើកុសលរបស់ព្រះអរហន្តដោយចំពោះ ។

កាមាវចរសោភណកិរិយាចិត្ត (មហាកិរិយាចិត្ត ) ៨ ដួង ជាចិត្តរបស់ព្រះអរហន្ត ជាចិត្តមិនមែនជាកុសលនិងមិនមែនជាអកុសលទាំងឡាយ ដែលជាហេតុឲ្យកើតវិបាកចិត្តក្នុងកាលខាងមុខ ។

សភាពនៃសោភណចិត្ត ដែលជាកុសលមុនព្រះអរហន្ត ពេលណាដែលព្រះអរហត្តមគ្គញាណកើតឡើង ហើយចិត្តជាកុសលនោះ ឈ្មោះថាកិរិយាចិត្ត ដែលមិនមែនជាហេតុឱ្យកើតវិបាកចិត្តតទៅទៀត ។ ដូច្នេះ បានជាព្រះអរហន្ត ទើបមានតែវិបាកចិត្តនិងកិរិយាចិត្តប៉ុណ្ណោះ ។ វិបាកក្នុងទីនេះ គឺវិបាកចិត្តដែលជាផលរបស់អតីតកម្មមុនជាព្រះអរហន្ត និងមានកិរិយាចិត្តដែលមិនមែនកុសលទើបមិនជាហេតុឱ្យកើតវិបាកចិត្តក្នុងកាលតទៅទៀត ។

# មហាកិរិយាចិត្ត ៨ដួង គឺ
## មហាកិរិយាចិត្តដួងទី ១

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា មិនបានអាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៥

| | |
|---|---|
| -អញ្ញសមានាចេតសិក | ១៣ |
| - សោភណចេតសិក | ២២ |

(វៀរវិរតិចេតសិក ៣ ) ។

### ចែកជាខន្ធ

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| - សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| - ចេតសិក ៣៣ | ជាសង្ខារក្ខន្ធ |
| - មហាកិរិយាចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

### ចែកជាធាតុ

| | |
|---|---|
| -ចេតសិក ៣៥ | ជាធម្មធាតុ |
| -មហាកិរិយាចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

## ចែកជាអាយតន

-ចេតសិក ៣៥ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៥ ជាទុក្ខសច្ច

-មហាកិរិយាចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

ជីវិតមានទ្រព្យ តែអត់មានធម៌ល្អក្នុងចិត្តសន្តាន អត់សម្បូរទ្រព្យទេ តែមានធម៌ល្អក្នុងចិត្តសន្តាន មានសេចក្តីស្ងប់ចិត្ត ទាំងពីរប្រការនេះ តើអ្នកជ្រើសរើសយកមួយណា ? ។

# ធម៌អប់រំចិត្ត

## *ស្ដីអំពី មិនបានចាក់ធ្លុះធម៌ ៤ យ៉ាង*

( ចាក.បិ.លេខ ១៦.ទំ.២៥៨ )

ព្រះដ៏មានព្រះភាគ បានត្រាសនឹងភិក្ខុទាំងឡាយថា៖ ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងសង្សារវដ្ដ ) អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ទាំង ៤ យ៉ាង ។ ធម៌ទាំង ៤ យ៉ាង តើដូចម្ដេច ?

ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹងមិនបានចាក់ធ្លុះនូវអរិយសីល ។

ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសមាធិ។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយបញ្ញា ។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយវិមុត្តិ ។

## មហាកិរិយាចិត្តជួនទី ២

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃបបួលដឹកនាំ ។

### មានចេតសិកប្រកប ៣៥

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២២ ( វៀរវិរតិចេតសិក ៣ ) ។

## ចែកជាខន្ធ

- វេទនាចេតសិក ជាវេទនាខន្ធ
- សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ៣៣ ជាសង្ខារក្ខន្ធ
- មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

- ចេតសិក ៣៥ ជាធម្មធាតុ
- មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

- ចេតសិក ៣៥ ជាធម្មាយតន
- មហាកិរិយាចិត្ត ជាមនាយតន ។

## ចែកជាសច្ច

- ចេតសិក ៣៥ ជាទុក្ខសច្ច
- មាហាកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី អានិសង្សការចាក់ធ្លុះធម៌ ៤ យ៉ាង*

( ចាក.បិ.លេខ ១៦.ទំ.២៥៩ )

ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយសមាធិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយបញ្ញាដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយវិមុត្តិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហាគឺសេចក្តីប្រាថ្នាក្នុងភពក៏សូន្យទៅ ខ្សែគឺតណ្ហាដែលអាចនាំសត្វពីភពមួយទៅភពមួយក៏អស់ទៅ ភពថ្មីទៀតក៏មិនមានក្នុងកាលឥឡូវនេះឡើយ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា ក៏ទ្រង់ត្រាស់ដូច្នេះតទៅទៀតថា ៖

ធម៌ទាំងអស់នេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិដ៏ប្រសើរ ព្រះគោតមព្រះអង្គមានយស បានត្រាស់ដឹងហើយ ព្រះសាស្តាមានចក្ខុទ្រង់ធ្វើនូវព្រះនិព្វាន ឲ្យជាទីបំផុតនៃកងទុក្ខ ទ្រង់បរិព្វានហើយ ។

# មហាកិរិយាចិត្តដួងទី ៣

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា មិនបានអាស្រ័យអ្នកដទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៤

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២១

( វៀរវិរតិ ៣ បញ្ញាចេតសិក ១ ) ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

- ចេតសិក ៣៤ ជាធម្មធាតុ

-មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៤ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣៤ ជាទុក្ខសច្ច

- មាហាកិរិយាចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

*ស្តីអំពី ប្រយោជន៍ព្រះអរិយៈ*

( ចាក.បិ.លេខ ៣៨.ទំ.២២៩ )

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងគុហាឈ្មោះ សូករខាតានាភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាសនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រពពិចារណាឃើញនូវអំណាចប្រយោជន៍ដូចម្តេច ? ទើបប្រព្រឹត្តធ្វើនូវសេចក្តីកោតក្រែង ដ៏ក្រៃលែងក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

ព្រះសារីបុត្តក្រាបទូលចំពោះ ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះតែភិក្ខុជាខីណាស្រពពិចារណា ឃើញនូវព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈ ដោយពិត ទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែងដ៏ក្រៃលែងក្នុងព្រះតថាគតផង ក្នុងសាសនារបស់តថាគតផង។

**នត្ថិ សន្តិ បរំ សុខំ**

*ពុំមានសេចក្តីសុខដទៃ ក្រៅពីសេចក្តីស្ងប់ឡើយ ។*

↓

ស្ងប់ពិត

↓

ស្ងប់កិលេស ស្ងប់ខន្ធ

↓ ↓

សឧបាទិសេសនិព្វាន អនុបាទិសេសនិព្វាន

# មហាកិរិយាចិត្តដួងទី ៤

**៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ប្រាសចាកបញ្ញាមានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ។

## មានចេតសិកប្រកប ៣៤

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២១

(វៀរវិរតិ ៣ និងបញ្ញា ១)

## ចែកជាខន្ធ

-វេទនាចេតសិត ជាវេទនាខន្ធ

-សញ្ញាចេតសិត ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣៤ ជាធម្មធាតុ

- មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣៨ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន

## ចែកជាសច្ច

-ចេតសិក ៣៨ ជាទុក្ខសច្ច

-មហាកិរិយាចិត្ត ជាទុក្ខសច្ច ។

## ✍ខ្លឹមសារគួរយល់ដឹង

ព្រះពុទ្ធសាសនា ប្រសូតចេញពីព្រះសម្មាសម្ពុទ្ធ ព្រះសម្មាសម្ពុទ្ធប្រសូតចេញពីធម្មជាតិ ធម្មជាតិមានពិតដោយហេតុ-បច្ច័យ។ ដូច្នេះព្រះពុទ្ធសាសនា គឺសម្ដែងចេញនូវភាពជាក់ស្ដែង ពោលគឺបង្ហាញប្រាប់អំពីធម្មជាតិហ្នឹងឯង។

# ធម៌អប់រំចិត្ត

## *ស្តីអំពី ព្រះអរហត្តជាធម៌ដ៏ប្រសើរ*

(ចាក.បិ.លេខ ៣៨.ទំ.២៣០)

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានពុទ្ធដីកា ទ្រង់សួរចំពោះព្រះសារីបុត្តថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រពពិចារណាឃើញព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាក យោគៈ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ក្នុងព្រះតថាគត ផងក្នុសាសនារបស់ព្រះតថាគតផង តើដូចម្តេចខ្លះ? ។

ព្រះសារីបុត្ត ក្រាបទូលចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ចម្រើនវីរិយិន្ទ្រិយ ។ ចម្រើនសតិន្ទ្រិយ ។ ចម្រើនសមាធិន្ទ្រិយ ។ ចម្រើនបញ្ញិន្ទ្រិយ ។ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ជាដំណើរ ទៅកាន់សេចក្តីត្រាស់ដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ពិចារណាព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈនេះឯង ទើបប្រព្រឹត្តធ្វើសេចក្តីកោត

ក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

# មហាកិរិយាចិត្តដួងទី ៥

**៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា មិនអាស្រ័យអ្នកដទៃ បបួលដឹកនាំ។

## មានចេតសិកប្រកប ៣៤

-អញ្ញសមានាចេតសិត ១២ ( វៀរបីតិ)

-សោភណចេតសិក ២២

(វៀរវិរតិចេតសិត ៣)

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

- សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ។

## ចែកជាធាតុ

-ចេតសិក ៣៨ ជាធម្មធាតុ

-មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ។

## ចែកជាអាយតន

-ចេតសិក ៣៨ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន។

## ចែកជាសច្ច

-ចេតសិក ៣៨ ជាទុក្ខសច្ច

-មហាកិរិយាចិត្ត ជាទុក្ខសច្ច។

## ✍ខ្លឹមសារគួរយល់ដឹង

នៅពេលខ្លះ មនុស្សយើងច្រើនតែមាក់ងាយវាយតម្លៃអ្នកដទៃ ជាយ៉ាងនេះ យ៉ាងនោះ ដោយពុំមានការពិចារណា ថ្លឹងថ្លែងឲ្យច្បាស់លាស់ ធ្វើឲ្យចិត្តមានសត្រូវកាន់តែច្រើនឡើងៗ ហើយពេលនោះចិត្តពុំមានមេត្តានិងមុទិតាឡើយ ។

# ធម៌អប់រំចិត្ត

## ស្តីអំពី ការកោតក្រែងរបស់ព្រះខីណាស្រព

(ចាក .បិ.លេខ ៣៨.ទំ.២៣១)

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សួរ ចំពោះព្រះសារីបុត្ត ថា ម្នាលសារីបុត្ត ចុះភិក្ខុជាខីណាស្រព ដែលមានសេចក្តីកោតក្រែងដ៏ប្រសើរ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុសាសនារបស់ព្រះតថាគតផង តើដូចម្តេចខ្លះ? ។

ព្រះសារីបុត្តក្រាបទូលចំពោះព្រះអង្គថា បពិត្រព្រះ-អង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពក្នុងសាសនានេះ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងព្រះសាស្តា ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តី កោតក្រែងក្នុងព្រះសង្ឃ ក្នុងសិក្ខា ក្នុងសមាធិ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ដែលមានសេចក្តីកោតក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង យ៉ាងនេះឯង។

✍ *បុគ្គលអ្នកធ្វើនូវសេចក្តីគោរពកោតក្រែង ចាប់ផ្តើមពីខ្លួនឯងឡើងទៅ ឈ្មោះថាជាមនុស្សល្អ ។*

# មហាកិរិយាចិត្តដួងទី ៦

**៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ។

## មានចេតសិកប្រកប ៣៤

-អញ្ញសមានាចេតសិក ១២

(វៀរបីតិចេតសិក )

-សោភណចេតសិក ២២

(វៀរវិរតិចេតសិក ៣) ។

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

- សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ។

## ចែកជាធាតុ

-ចេតសិក ៣៤ ជាធម្មធាតុ

-មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ។

## ចែកជាអាយតន

-ចេតសិក ៣៨ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន។

## ចែកជាសច្ច

-ចេតសិក ៣៨ ជាទុក្ខសច្ច

-មហាកិរិយាចិត្ត ជាទុក្ខសច្ច។

## ✍ខ្លឹមសារគួរយល់ដឹង

មនុស្សបើមិនមានសេចក្ដីសង្ឃឹមទេ ការខកចិត្តក៏មិនមានដែរ ដូច្នេះបើមិនចង់ខកចិត្តទេ ទាល់តែកុំមានការសង្ឃឹម ។ ដូចជាសង្ឃឹមក្នុងរបស់ទាំងពួងរាល់ថ្ងៃនេះ សង្ឃឹមខន្ធមិនទៀង សង្ឃឹមខន្ធជាទុក្ខ សង្ឃឹមខន្ធជាអនត្តា ជាទីបំផុតខកចិត្តស្ដាប់ធម៌ក៏លែងយល់ដែរ។

*✍កិច្ចការងាររបស់មនុស្សយើង សំខាន់ធំៗ ២យ៉ាង គឺ លះបាប ១ ចម្រើនបុណ្យ ១ ។*

# ធម៌អប់រំចិត្ត

## *ស្ដីអំពី ប្រយោជន៍ព្រហ្មចរិយៈ*

(ចាកបិ.លេខ ៨៨.ទំ.២៩៩)

ខ្ញុំបានស្ដាប់មកយ៉ាងនេះ។ សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់ក្នុងវត្តឃោសិតារាម ជិតក្រុងកោសម្ពី។ លំដាប់នោះឯង ព្រហ្មណ៍ឈ្មោះ ឧណ្ណាភៈ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររំលឹកហើយ ក៏ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ឈ្មោះ ឧណ្ណាភៈ អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះអានន្ទ ដ៏មានអាយុ ដូច្នេះថា:

បពិត្រព្រះអានន្ទដ៏ចម្រើន គេប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់ព្រះសមណគោត្តម មានអ្វីជាប្រយោជន៍ ?

ព្រះអានន្ទដ៏មានអាយុឆ្លើយថា ម្នាលព្រាហ្មណ៍ឧណ្ណាសកៈ គេប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់ព្រះដ៏មានព្រះភាគ មានការលះបង់នូវឆន្ទៈជាប្រយោជន៍ ។

# មហាកិរិយាចិត្តដួងទី ៧

**៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា មិន បានអាស្រ័យអ្នកដ៏ទៃ បបួលដឹកនាំ ។

## មានចេតសិកប្រកប ៣៣

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក)

-សោភណចេតសិក ២១ (វៀរវិរតិ៣ បញ្ញាចេតសិក ១)

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ។

## ចែកជាធាតុ

-ចេតសិក ៣៣ ជាធម្មធាតុ

-មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ។

## ចែកជាអាយតន

-ចេតសិក ៣៣ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន។

## ចែកជាសច្ច

- ចេតសិក ៣៣ ជាទុក្ខសច្ច
-មហាកិរិយាចិត្ត ជាទុក្ខសច្ច។

# ធម៌អប់រំចិត្ត

*ស្ដីអំពី កាយគតាសតិ*

(ចាក.បិ.លេខ ៤០.ទំ.៩៥)

ម្នាលភិក្ខុទាំឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចម្រើនហើយ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីសង្វេគច្រើន តែប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើនច្រើន តែងប្រព្រឹត្តទៅដើម្បីសេចក្ដីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅដើម្បីបាននូវសតិនិងសម្បជញ្ញៈ តែងប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ តែងប្រព្រឹត្តទៅនៅជាសុខក្នុងបច្ចុប្បន្ន តែប្រព្រឹត្តទៅដើម្បីធ្វើឱ្យជាក់ច្បាស់នូវវិជ្ជា វិមុត្តិ និងផល។ ធម៌មួយយ៉ាងគឺអ្វី។ គឺកាយគតាសតិ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចម្រើនហើយបានធ្វើឱ្យរឿយៗហើយ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីសង្វេគ

ច្រើន ដើម្បីសេចក្ដីចម្រើនច្រើន ដើម្បីសេចក្ដីក្សេមចាកយោគៈច្រើន ដើម្បីបាននូវសតិ និងសម្បជញ្ញៈ ដើម្បីបាននូវញាណទស្សនៈ ដើម្បីនៅជាសុខក្នុងអត្តភាពនេះ ដើម្បី ធ្វើឱ្យជាក់ច្បាស់នូវវិជ្ជា[2] វិមុត្តិ[3] និង ផល[4] ។

## មហាកិរិយាចិត្តដួងទី ៨

**៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនាប្រាសចាក បញ្ញា មានកម្លាំងទន់ខ្សោយ អាស្រ័យអ្នកដទៃ បបួលដឹកនាំ។

## មានចេតសិកប្រកប ៣៣

-អញ្ញសមានាចេតសិក ១២ (វៀរបីតិចេតសិក)

-សោភណចេតសិក ២១ (វៀរវិរតិ ៣ បញ្ញាចេតសិក ១)

---

[2] *បានដល់បញ្ញាដែលសម្បយុត្តដោយមគ្គ ១*

[3] *បានខាងសម្បយុត្តធម៌ដែលកើត រលត់ជាមួយគ្នាដោយមគ្គប្បញ្ញានេះ*

[4] *បានខាងអរហត្តផល ។*

## ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ

-មហាកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ។

## ចែកជាធាតុ

-ចេតសិក ៣៣ ជាធម្មធាតុ

-មហាកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ។

## ចែកជាអាយតន

-ចេតសិក ៣៣ ជាធម្មាយតន

-មហាកិរិយាចិត្ត ជាមនាយតន

## ចែកជាសច្ច

-ចេតសិក ៣៣ ជាទុកសច្ច

-មហាកិរិយាចិត្ត ជាទុក្ខសច្ច។

## ✍ខ្លឹមសារគួរយល់ដឹង

មនុស្សយើងគួរតែប្រយ័ត្នក្នុងពាក្យសម្ដី ពាក្យសម្ដីប្រៀបបាននឹងអាវុធដ៏មុត គឺអាចគ្រោះថ្នាក់ដល់ខ្លួនឯងនិងអ្នកដទៃ ប៉ុន្តែសម្ដីអាចញ៉ាំងប្រយោជន៍ ឱ្យអ្នកដទៃបានផងដែរ។

# ធម៌អប់រំចិត្ត

## *ស្តីអំពី បរិស័ទស្រកេកស្រកាក និងផូរផង់*

(ចាក.បិ.លេខ ៤០.ទំ.១៦១)

ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក។ បរិស័ទ ២ ពួក តើដូចម្តេច ? ។ គឺបរិស័ទស្រកេកស្រកាក ១ បរិស័ទផូរផង់ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទស្រកេកស្រកាក តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ លុះក្នុងអំណាចឆន្ទាគតិ លុះក្នុងអំណាចទោសាគតិ លុះក្នុងអំណាចមោហាគតិ លុះក្នុងអំណាចភយាគតិក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនោះហៅថា បរិស័ទស្រកេកស្រកាក។

ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទផូរផង់ តើដូចម្តេច? ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មិនលុះក្នុងអំណាចឆន្ទាគតិ មិនលុះក្នុងអំណាចទោសាគតិ មិនលុះក្នុងអំណាចភយាគតិក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័នោះហៅថា បរិស័ទផូរផង់។

ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទ ២ ពួកនេះ បរិស័ទផ្ទុយផង់នុ៎ះទើបប្រសើរ ។ បុគ្គលណាដែលមានខ្លួនក្នុងភាពជាអ្នកដឹកនាំ មិនត្រូវយកអគតិធម៌ណាមួយមកដាក់ក្នុងខ្លួនឡើយ ព្រោះអគតិធម៌នេះ ធ្វើឱ្យសព្រហ្មចារីដែលអាស្រ័យនៅជាមួយនឹងខ្លួន ពុំមានសេចក្តីសុខ ពុំមានសេចក្តីស្ងប់ឡើយ។

# អធិប្បាយបន្ថែមមហាកុសលចិត្ត ៨ ដួង

(*ស្រង់ចាក់គម្ពីរ អភិធម្មត្ថសង្គហៈ*)

ក្នុងបណ្តាលមហាកុសលចិត្ត ៨ ដួងនោះ អាចដើម្បីសង្កេតយ៉ាងនេះគឺៈ

(*កុសលចិត្តទី១*) ក្នុងកាលណា បុគ្គលដែលបរិបូណ៌ដោយទេយ្យធម៌ (បានដល់វត្ថុដែលត្រូវឱ្យជាទាន) និងបដិគ្គាហកៈ (អ្នកទទួលនូវទេយ្យធម៌នោះ) ជាដើម ឬហេតុនៃសោមនស្សយ៉ាងដទៃ មានសេចក្តីត្រេកអររីករាយធ្វើសម្មាទិដ្ឋិឱ្យប្រព្រឹត្តទៅដោយន័យថា «ទានដែលបុគ្គលឱ្យហើយរមែងមានផល» ដូច្នេះជាដើម ហើយមិនចាំបាច់

ឱ្យអ្នកដទៃណាមកបបួលទេ ប្រឹងប្រែងធ្វើបុណ្យមានការឱ្យទានជាដើម ក្នុងកាលនោះ ចិត្តរបស់បុគ្គលនោះ ជាចិត្តដែលសហគតដោយសោមនស្ស ប្រកបដោយបញ្ញា ឬសម្បយុត្តដោយញាណ ជាអសង្ខារិក មិនមានអ្នកដទៃបបួលដឹកនាំ។

(*កុសលចិត្តដួងទី ២*) កាលណាបុគ្គលមានសេចក្តីត្រេកអររីករាយ ដោយន័យដូចដែលពោលហើយ មានសម្មាទិដ្ឋិនៅខាងមុខ ប៉ុន្តែចិត្តរារែកដោយភាពជាអ្នកកំណាញ់ «គឺមិនចង់ឱ្យ» តែត្រូវអ្នកដទៃមកបបួលដឹកនាំទើបធ្វើបុណ្យក្នុងកាលនោះ ចិត្តរបស់បុគ្គលនោះឯង រមែងជាចិត្ត ដែលសហគតដោយសោមនស្សសម្បយុត្តញាណជាសសង្ខារិកអាស្រ័យអ្នកដទៃបបួលដឹកនាំ។

( *កុសលចិត្តដួងទី ៣* ) ក្នុងកាលណា ពេលដែលក្មេងឥតដឹងក្តី មានការធ្លាប់ដោយឃើញបដិបត្តិរបស់ជនជាញាតិដូចជាឃើញភិក្ខុសង្ឃ ហើយក៏កើតសោមនស្សរមែងប្រគេនវត្ថុដែលមាននៅក្នុងដៃ យ៉ាងណាមួយ ឬរមែងសំពះដោយរួសរាន់ក្នុងកាលនោះ ចិត្តដួងទី ៣ ព្រមដោយសោមនស្ស មិនប្រកបដោយញាណ ជាអសង្ខារិករមែងកើតឡើងដល់ពួកក្មេងដែលឥតដឹងក្តីនោះ។

( *កុសលចិត្តដួងទី ៤* ) ក្នុងកាលណាក្មេងឥតដឹងក្តីទាំងនោះ ត្រូវពពួកញាតិឱ្យឧស្សាហ: « បបួល » ថា អ្នកចូរប្រគេន ចូរឱ្យ ចូរសំពះ ដូច្នេះ ក៏បដិបត្តិតាមក្នុងកាលនោះ ចិត្តដួងទី ៤ ព្រមដោយសោមនស្ស មិនប្រកបដោយញាណ ជាសសង្ខារិករបស់ក្មេងនោះរមែងកើតឡើង ។

មហាកុសលចិត្ត ៤ដួងដទៃក្រោយទៀត ជាចិត្តសហគតដោយឧបេក្ខាវេទនា លោកពោលទុកថា ម៉្យាងទៀតក្នុងកាលណា បុគ្គលមិនបរិបូណ៌ដោយទេយ្យធម៌និងបដិគ្គាហក:ជាដើម ឬ មិនមានហេតុឱ្យសោមនស្សយ៉ាងដទៃកើតឡើង ទើបវៀរចាកសោមនស្សវេទនាក្នុងកាលនោះ មហាកុសលចិត្តក៏សហគតដោយឧបេក្ខា ៤ដួង ដែលនៅសល់ពីសោមនស្សវេទនា ៤ ដួង ។ គឺចិត្តសហគតដោយឧបេក្ខា ប្រកបដោយញាណ ជាអសង្ខារិក ១ សសង្ខារិក ១ ចិត្តសហគតដោយឧបេក្ខាប្រាសចាកញាណ ជាអសង្ខារិក ១សសង្ខារិក ១។

# វិធីរាប់កុសលចិត្តដោយពិស្តារ

(*ស្រង់ចាក អភិធម្មត្ថសង្គហៈ*)

អាចារ្យទាំងឡាយបានចងគាថាទុកថាៈ

**កមេន បុញ្ញវត្ថូហិ គោចរាធិបតីហិ ច**
**កម្មហីនាទិតោ ចេវ គណេយ្យ នយកោវិទោតិ ។**

អ្នកឆ្លាតក្នុងន័យ គប្បីរាប់នូវចិត្តទាំងឡាយ ដោយបុញ្ញកិរិយាវត្ថុ ១០ ដោយគោចរគឺអារម្មណ៍ ៦ ដោយអធិបតី ៤ ដោយកម្ម ៣ ដោយចិត្តថោកទាបជាដើម ៣ តាមលំដាប់។

គប្បីជ្រាបវិធីរាប់កុសលចិត្តក្នុងន័យ ៥ ចំនុចដូច្នេះគឺៈ

១-មហាកុសលចិត្ត ៨ គុណនឹងបុញ្ញកិរិយាវត្ថុ ១០ ជា ៨០ដួង។

២-មហាកុសលចិត្ត ៨០ គុណនឹងអារម្មណ៍ ៦ ជា ៤៨០ ដួង។

៣-មហាកុសលចិត្ត ៤៨០ ចែកជា ២ គឺចិត្តដែលជាញាណសម្បយុត្ត ២៤០ ដួង ជាញាណវិប្បយុត្ត ២៤០ ដួងដូច្នេះ ចិត្តដែលសម្បយុត្តដោយញាណ ២៤០ ដួង គុណនឹងអធិបតី ៤ បាន ៩៦០ដួង ចិត្ត

ជាញាណវិប្បយុត្ត ២៤០ ដួងគុណនឹងអធិបតី ៣ បាន ៧២០ដួង រួមបានចិត្ត ១៦៨០ដួង ។

៤-ចិត្ត ១៦៨០ ដួងគុណនឹងកម្ម ៣ បានចិត្ត ៥០៤០ ដួង ។

៥-ចិត្ត ៥០៤០ ដួង គុណនឹងចិត្តថោកទាបកណ្ដាល ប្រណីត បានចិត្ត ១៥១២០ ដួង ។

## ហេតុ-បច្ច័យនៃធម៌ផ្សេងៗ

## ហេតុឲ្យកើតកុសលសោមនស្ស ៦ យ៉ាង

*(ស្រង់ចាកអភិធម្មត្ថសង្គហៈ)*

**១-សោមនស្សបដិសន្ធិកតា** បដិសន្ធិដោយសោមនស្ស

**២-សទ្ធាពហុលតា** ជាអ្នកច្រើនដោយសទ្ធា

**៣-វិសុទ្ធទិដ្ឋិតា** មានការឃើញប្រាសចាកមន្ទិល

**៤-អានិសំសទស្សាវិតា** ឃើញអានិសង្សរបស់កុសល

**៥-ឥដ្ឋារម្មណសមាយោគោ** ប្រសព្វជាមួយនឹងឥដ្ឋារម្មណ៍

**៦-ឝស្សចិបិឡាតាភោ** មិនមានឧបសគ្គរារាំ ។

# ហេតុឲ្យកើតកុសលឧបេក្ខា ៦ យ៉ាង

**១-ឧបេក្ខាបដិសន្ធិកតា** បដិសន្ធិដោយឧបេក្ខា

**២-អប្បសទ្ធតា** ជាអ្នកមានសទ្ធាតិច

**៣-អវិសុទ្ធទិដ្ឋិតា** មានការយល់ឃើញមិនបរិសុទ្ធ

**៤-អានិសំសអទស្សាវិតា** មិនឃើញអានិសង្សរបស់កុសល

**៥-មជ្ឈត្តារម្មណសមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ប្រភេទកណ្តាល

**៦-ភស្សចិបិឡិតតា** មានឧសគ្គរាំរាំ ។

***<u>ហេតុឲ្យកើតកុសលញាណសម្បយុត្ត ៤</u>*** *(ន័យទី ១)*

**១-បញ្ញាសំវត្តនិកកម្មូបនិស្សយតា** ភាពជាអ្នកមានឧបនិស្ស័យក្នុងការធ្វើកុសល ដែលប្រកបដោយបញ្ញា ។

**២-អព្យាបជ្ជលោកូប្បត្តតា** ភាពជាអ្នកកើតឡើងក្នុងលោកដែលមិនមានការបៀតបៀន ។

**៣-ឥន្ទ្រិយបរិបាកតា** ភាពជាអ្នកមានឥន្ទ្រិចាស់ក្លា ។

**៤-កិលេសទូរតោ** ភាពជាអ្នកឆ្ងាយចាកកិលេស។

***<u>ហេតុឲ្យកើតកុសលញាណសម្បយុត្ត ៧</u>*** (ន័យទី ២)

**១-បរិបុច្ឆកតា** ជាអ្នកចេះសាកសួរក្នុងបញ្ហាផ្សេងៗ

**២-វត្ថុវិសទក្រិយតា** ការស្អាតទាំងកាយ ចិត្ត និង វត្ថុ

**៣-ឥន្ទ្រិយសមត្តបដិបាទនតា** មានឥន្ទ្រិយទាំ ៥ ស្មើគ្នា

**៤-ទុប្បញ្ញាបុគ្គលបរិវជ្ជនា** គេចចេញពីអ្នកដែលមានបញ្ញាខ្សោយ

**៥-បញ្ញាវន្តបុគ្គលសេវនតា** សមាគមនឹងអ្នកដែលមានបញ្ញា

**៦-គម្ភីរញាណចរិយបច្ចវេក្ខណា** ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ

**៧-តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងញាណនោះ ។

***<u>ហេតុឲ្យកើតកុសលញាណវិប្បយុត្ត ៤</u>*** (ន័យទី ១)

**១-បញ្ញាអសំវត្តនិកកម្មូបនិស្សយតា** ភាពជាអ្នកមានឧបនិស្ស័យក្នុងការធ្វើកុសល មិនប្រកបដោយបញ្ញា

**២-សព្យាបជ្ជលោកូប្បត្តិតា** ភាពជាអ្នកកើតឡើងក្នុងពេលណា ដែលមានការបៀតបៀន

**៣-ឥន្ទ្រិយអបរិបាកតា** ភាពជាអ្នកមានឥន្ទ្រិយទន់ខ្សោយ

**៤-កិលេសាទូរតា** ភាពជាអ្នកមិនឆ្ងាយចាកកិលេស ។

***<u>ហេតុឲ្យកើតកុសលញាណវិប្បយុត្ត ៧</u>*** (ន័យទី ២)

**១-អបរិបុច្ឆកតា** ភាពជាអ្នកមិនចេះសាកសួរ

**២-វត្ថុអវិសទតា** ការមិនស្អាតទាំងកាយ ចិត្ត និងវត្ថុ
**៣-ឥន្ទ្រិយអសមត្តបដិបាទនតា**
មិនបរិបូណ៌ដោយឥន្ទ្រិយ
**៤-ទុប្បញ្ញាបុគ្គលសេវនា** សេពគប់អ្នកមិនមានបញ្ញា
**៥-បញ្ញវន្តបុគ្គលបរិវជ្ជនា** គេចចេញពីអ្នកមានបញ្ញា
**៦-គម្ភីរញាណចរិយបច្ចវេក្ខណា** មិនពិចារណានូវ
ញាណចរិយាដ៍ជ្រាលជ្រៅ
**៧-អតទធិមុត្តតា** ជាអ្នកបង្អោនចិត្តទៅក្នុងញាណនោះ។

## *ហេតុឲ្យកើតអសង្ខារិកចិត្ត ៦ យ៉ាងគឺ*

**១-អសង្ខារិកកម្មជនិតបដិសន្ធិកតា** ជាអ្នកបដិសន្ធិ
ដោយកម្មជាអសង្ខារិក
**២-កល្លកាយចិត្តតា** ជាអ្នកមានកាយនិងចិតរឹងប៉ឹងមាំមួន
**៣-សីតុណ្ហាទីនំ ខមនពហុលតា** អត់ធន់ចំពោះ
ត្រជាក់ និងក្ដៅជាដើម
**៤-កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** ជាអ្នកឃើញប្រយោជន៍
ក្នុងការងារដែលគប្បីធ្វើ
**៥-កម្មេសុ ចិណ្ណវសិតា** ជាអ្នកមានជំនាញក្នុងការងារ

ទាំងឡាយ

**៦-ឧតុភោជនាទិសប្បាយលោភោ** បានសេចក្តីសប្បាយចិត្តក្នុងឧតុ និងភោជន ជាដើម។

## ចែកកុសលដោយឧក្កដ្ឋៈ និងឱមកជា ៤

**១-តិហេតុក** ប្រភេទឧក្កដ្ឋៈ (**ឧក្រិដ្ឋ**)

**២-តិហេតុក** ប្រភេទឱមកៈ (**ថ្នាក់បន្ទាប់**)

**៣-ទ្វិហេតុក** ប្រភេទឧក្កដ្ឋៈ (**ថ្នាក់ឧក្រិដ្ឋ**)

**៤-ទ្វិហេតុក** ប្រភេទឱមកៈ (**ថ្នាក់បន្ទាប់**)

## *ចែកកុសលដោយឧក្កដ្ឋ និង ឱមក ៨*

**១-តិហេតុកកុសលឧក្កដ្ឋ** ថ្នាក់ទី ១ តិហេតុកឧក្កដ្ឋុក្កដ្ឋៈ

**២-តិហេតុកកុសលឧក្កដ្ឋ** ថ្នាក់រង តិហេតុកឧក្កដ្ឋោមកៈ

**៣-តិហេតុកកុសលឱមក** ថ្នាក់ទី ១ តិហេតុកឱមកុក្កដ្ឋៈ

**៤-តិហេតុកកុសលឱមក** ថ្នាក់រង តិហេតុកឱមកោមកៈ

**៥-ទ្វិហេតុកកុសលឧក្កដ្ឋ** ថ្នាក់ទី ១ ទ្វិហេតុកឧក្កដ្ឋុក្កដ្ឋៈ

**៦-ទ្វិហេតុកកុសលឧក្កដ្ឋ** ថ្នាក់រង ទ្វិហេតុកដ្ឋោមកៈ

**៧-ទ្វិហេតុកកុសលឱមក** ថ្នាក់ទី១ ទ្វិហេតុកឱមកុក្កដ្ឋៈ

**៨-ទ្វិហេតុកកុសលឱមក** ថ្នាក់រង ទ្វិហេតុកឱមកោមកៈ

រួមជាកុសល ៨ ប្រការ តាមដែលបានពោលមកនេះ អាស្រ័យមុញ្ចនចេតនាជាប្រធាន គឺខណៈដែលមុញ្ចន-ចេតនាកើតឡើង ប្រកបដោយហេតុ ៣ ក៏ជាតិហេតុក កុសល បើមុញ្ចនចេតនា ប្រកបដោយហេតុ ២ កុសល នោះ ក៏ឈ្មោះថា *ទ្វិហេតុកកុសល* ។

## *អធិប្បាយបន្ថែមមហាវិបាកចិត្ត ៨ ដួង*

*(ស្រង់ចាកអភិធម្មត្ថសង្គហៈ)*

មហាកុសល ៨ ដួង ជាបច្ច័យឲ្យផល ជាសហេតុក វិបាកចិត្ត ៨ ដួង ហើយឱ្យផលជាអហេតុក កុសលវិបាក ចិត្ត ៨ ដួងទៀត រួមជាកុសលវិបាក ១៦ ដួង តែការ ឱ្យផលរបស់វិបាកទាំង ២ ប្រភេទនេះ ផ្សេងៗគ្នាគឺ

បណ្តាលអហេតុកកុសលវិបាក មានអហេតុកកុសល វិបាកឧបេក្ខាសន្តីរណចិត្ត ១ ធ្វើបដិសន្ធិកិច្ចក្នុងមនុស្ស ភូមិ ១ ក្នុងចាតុម្មហារាជកាភូមិ ១ ក្នុងបវត្តិកាល អហេតុកកុសលវិបាក ៨ ដួង កើតឡើងទទួលផលរបស់

កុសលកម្ម ក្នុងកាមភូមិ ១១ ក្នុងរូបភូមិ ១៥ វៀរអសញ្ញិ-សត្តាភូមិ តាមសមគួរដល់ទ្វារ និងអារម្មណ៍។

ចំណែកសហេតុកមហាវិបាកចិត្តទាំង ៨ ដូងនោះ ឱ្យផលបានកើតបានក្នុងសុគតិភូមិ ៧ ជាន់ប៉ុណ្ណោះ គឺឱ្យផលបដិសន្ធិក្នុងបដិសន្ធិកាល ក្នុងបវត្តិកាលជាភវង្គកិច្ច និងតទាលម្ពណកិច្ច។

## ផល ២ យ៉ាង

*(ក្នុងគម្ពីរអដ្ឋសាលនី)*

**១-មុខផល** ផលដោយត្រង់ បានដល់ធម៌ដែលជាវិបាក គឺចិត្តចេតសិកកើតឡើង ទទួលផលរបស់កម្មដែលធ្វើទុកហើយ។

**២-សាមញ្ញផល** បានដល់ផលដែលស្មើគ្នា ដែលជាផលដោយអម បានដល់កម្មជរូប មានហទយរូបជាដើម ដែលកើតព្រមនឹងចិត្តក្នុងបដិសន្ធិកាល ។ ក្នុងទីនេះ លោកប្រាថ្នាយកមុខផលដោយត្រង់ បានដល់មហាវិបាកចិត្ត ៨ ដួងនុ៎ះឯង ។ មហាវិបាកចិត្តនេះ កាលពោលដោយវេទនាក្តី សម្បយោគក្តី ការប្រកបនិងសង្ខារក្តី មានលក្ខណៈដូចគ្នានឹងមហាកុសលទាំង ៨ គ្រប់ប្រការ ។

# មហាវិបាកផ្សេងពីមហាកុសល

មហាកុសលទាំងឡាយ មានច្រើនដោយកម្ម ៣ ដោយទ្វារ ៦ ដោយកម្មបថ ១០ ដោយបុញ្ញកិរិយាវត្ថុ ១០ ចំណែកមហាវិបាក ៨ មិនមានសេចក្តីផ្សេងៗគ្នានៃកម្មទ្វារកម្មបថនិងបុញ្ញកិរិយាវត្ថុទេ សេចក្តីនេះ ព្រោះមហាវិបាកឱ្យវិញ្ញត្តិកើតមិនបាន គឺមហាវិបាកមិនធ្វើវិបាកឱ្យកើតទៀត និងព្រោះមហាវិបាកនោះ មិនប្រព្រឹត្តទៅដូចមហាកុសលចិត្ត។

មួយទៀត **ករុណា មុទិតា និង វិរតិ ៣ គឺ** សម្មាវាចា សម្មាកម្មន្តៈ សមាអាជីវៈ រួមទាំង ៥ យ៉ាងនេះ ជាមហាកុសលប៉ុណ្ណោះ ចំណែកមហាវិបាកមិនមានករុណាមុទិតា វិរតិ ៣ ទេ សេចក្តីនេះ ព្រោះករុណានិងមុទិតា មានសត្វជាអារម្មណ៍របស់មហាកុសល និងជាមហគ្គតអប្បមញ្ញាឈាន សូម្បីវិរតិ ៣ ក៏មិនមានក្នុងវិបាក ព្រោះព្រះដ៏មានព្រះភាគត្រាស់ថា សិក្ខាបទ ៥ ជាកុសលប៉ុណ្ណោះ។

វិបាកធម៌ ជាអសង្ខារិក និងសសង្ខារិកនោះ ដូចគ្នានឹងមហាកុសល គឺកុសលជាអសង្ខារិក វិបាកជាអសង្ខារិក កុសលជាសសង្ខារិក វិបាកជាសសង្ខារិក ។

ចំណែកក្នុងសេចក្តីផ្សេងគ្នា នៃកុសលចិត្តដែលអាក្រក់កណ្តាល (វិបាកនោះ) ក៏រមែងកណ្តាល វិបាករបស់កុសលដែលប្រណីត (វិបាកនោះ) ក៏រមែងប្រណីត ក្នុងវិបាកទាំងនេះ សូម្បីធម៌ដែលជាអធិបតីទាំងឡាយ មិនមានទេ សេចក្តីនេះ ព្រោះភាពនៃវិបាកទាំងនោះ មិនធ្វើឆន្ទៈជាដើម ឱ្យជាធុរៈហើយកើតឡើង ។

## ស្ថានដែលឲ្យកើតផលរបស់មហាវិបាក ៨ មាន ៤ ស្ថាន

**១-បដិសន្ធិស្ថាន** ដែលធ្វើកិច្ចបដិសន្ធិ

**២-ភវង្គស្ថាន** ដែលធ្វើកិច្ចរក្សាភពជាតិ

**៣-ចុតិស្ថាន** ដែលធ្វើកិច្ចឃ្លាតចាកភព

**៤-តទាលម្ពណស្ថាន** ដែលធ្វើកិច្ចទទួលអារម្មណ៍តពីជវនៈ។

*ស្សួរថា វិបាកទាំងនេះឱ្យផលយ៉ាងណា ?*

ឆ្លើយថា វិបាកទាំងនោះ ឱ្យផលបដិសន្ធិស្ថានមុន គឺក្នុងវេលាចាប់បដិសន្ធិ របស់អ្នកមានបុណ្យទាំងឡាយដែលជាទុហេតុកៈ និងតិហេតុកៈ ឱ្យផលកើតក្នុងពួកមនុស្ស ឬពួកទេវតាជាន់កាមាវចរៈ កាលបដិសន្ធិកិច្ច

រលត់ទៅហើយ ក៏ឱ្យផលជាភវង្គស្ថាន ក្នុងបវត្តិកាល រហូតដល់អស់អាយុ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ១ អសង្ខេយ្យ ឆ្នាំខ្លះ តាមសមគួរដល់អាយុរបស់សត្វ ដែលនៅក្នុងភព នោះៗ ឱ្យផលជាតទាលម្ពណស្ថាន ក្នុងអារម្មណ៍ដែល មានកម្លាំងក្នុងទ្វារ ៦ គឺ ទទួលអារម្មណ៍ តពីជវនចិត្ត តទាលម្ពណចិត្តនេះ កើតចំពោះតែក្នុងកាមសត្វ ដែល នៅក្នុងកាមភូមិប៉ុណ្ណោះ។ ឱ្យផលជាចុតិស្ថាន ក្នុងមរណ កាលនៃភពដែលរស់នៅនោះ គឺថាកាលណា មហាវិបាកចិត្ត ដែលប្រាកដគ្រាដំបូង (បដិសន្ធិ) ក្នុងភពនោះតាំងនៅ បន្តមកដរាបដល់វារៈដែលនឹងត្រូវឃ្លាតចាកភពជាតិ ហើយ មហាវិបាកចិត្តប្រភេទតែមួយ ដូចនឹងបដិសន្ធិនោះឯង ធ្វើចុតិកិច្ចឃ្លាតចាកភពនោះ មហាវិបាកចិត្ត ៨ នេះឱ្យ ផលក្នុងស្ថានទី ៤ ដោយប្រការយ៉ាងនេះ ។

## មហាវិបាកចែកសត្វឱ្យផ្សេងគ្នា

មហាវិបាក ៨ ដូងនេះ រមែងចែកសត្វឱ្យប្រព្រឹត្តទៅ តាមកម្ម គឺបដិសន្ធិក្នុងកាមសុគតិភូមិ ៧ តាមសមគួរ ដល់កម្លាំងរបស់មហាកុសលចិត្តនោះ នឹងធ្វើសត្វឱ្យ

ផ្សេងគ្នា សូម្បីកើតក្នុងភូមិតែមួយក៏ដោយ ក៏ការដែលកម្មចែកសត្វឱ្យផ្សេងគ្នា គឺព្រោះកិលេស និងកម្លាំសទ្ធាជាដើម ក្នុងអតីតកាល។ សូម្បីក្នុងការឱ្យទានដូចគ្នា ក៏វិបាករបស់ទាននោះ អាចញុំាងសត្វឱ្យកើតក្នុងទីផ្សេងៗគ្នា ដល់ ៧ កន្លែងគឺ ៖

**១-អ្នកណាឱ្យទាន** ដោយប្រាថ្នាផលតបមកវិញយ៉ាងណាមួយក្នុងភពខាងមុខ កាលស្លាប់ហើយ នឹងទៅកើតជាទេវតា ជាន់ចាតុម្មហារាជិកា ។

**២-អ្នកណាឱ្យទាន** ដោយមិនប្រាថ្នាផលតបមកវិញក្នុងភពខាងមុខទេ គឺឱ្យដោយគិតថា ការឱ្យទានជាការល្អ កាលស្លាប់ទៅហើយ នឹងទៅកើតជាទេវតា ជាន់តាវត្តិង្ស ។

**៣-អ្នកណាឱ្យទាន** ដោយគិតថា មាតា បិតា យាយតា ធ្លាប់ធ្វើមកហើយគួរធ្វើតទៅ មិនឱ្យខូច ប្រពៃណី កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់ យាមា។

**៤-អ្នណាឱ្យទាន** ដោយមេត្តាប្រាថ្នានឹងឱ្យអ្នកទទួលទានមានសេចក្ដីសុខ មិនមានសេចក្ដីលំបាក កាលស្លាប់ទៅហើយ នឹងទៅកើតជាទេវតាជាន់តុសិត ។

**៥-អ្នកណាឱ្យទាន** ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ អ្នកឱ្យទានកន្លងមកពីកាលមុន កាលស្លាប់ទៅហើយ នឹងកើតជាទេវតា ជាន់និម្មានរតី។

**៦-អ្នកណាឱ្យទាន** ដោយឃើញថា កាលឱ្យទានហើយ នឹងធ្វើចិត្តឱ្យរីករាយសោមនស្សកើតសេចក្តីជ្រះថ្លា កាលស្លាប់ហើយ នឹងទៅកើតជាទេវតា ជាន់បរនិម្មិតវសវត្តី ។

**៧-អ្នកណាឱ្យទាន** ដើម្បីជម្រះចិត្តឱ្យផូរផង់ បានឈានកាលស្លាប់ហើយ នឹងទៅកើតក្នុងព្រហ្មលោក ។

## អធិប្បាយបន្ថែមមហាកិរិយាចិត្ត ៨ ដួង

*(ស្រង់ចាកអភិធម្មត្ថសង្គហៈ)*

មហាកិរិយាចិត្ត ឬ កាមាវចរកិរិយាចិត្តនេះ មិនមែនជាកុសលចិត្ត មិនមែនជាអកុសលចិត្ត មិនមែនជាវិបាកចិត្ត ជាចិត្តអព្យាគត គឺត្រឹមតែការធ្វើប៉ុណ្ណោះ។

បណ្តាលអព្យាគតចិត្តទាំង ១១ គឺអហេតុកកិរិយាចិត្ត ៣ ដួង សហេតុកិរិយាចិត្ត ៨ដួង ចិត្តនេះមិនអាចមានផលទេ។ ពាក្យថា កិរិយាបានដល់ត្រឹមតែការធ្វើពិតណាស់ក្នុងកិរិយាចិត្តគ្រប់ដួងនោះ កិរិយាចិត្តណា មិន

ដល់ភាពជាជវនៈ កិរិយាចិត្តនោះរមែងមិនមានផល ដូចផ្កាឈើខ្យស់ ( **ខាតបុប្ផំ វិយ** ) កិរិយាចិត្តណាដល់ភាពជាជវនៈ កិរិយាចិត្តនោះ ក៏មិនមានផលដូចផ្កាឈើ (គឺផ្កាដែលត្រូវមានផ្លែនៅជាប់ដើម) ដែលមានឫសដាច់ហើយ កិរិយាចិត្តទាំងនេះ គឺត្រឹមតែជាការធ្វើប៉ុណ្ណោះព្រោះ ប្រព្រឹត្តទៅដោយអំណាចការញុំាងកិច្ចនោះៗ ឱ្យសម្រេច ដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា កិរិយា (ការធ្វើ) ។

ក្នុងអហេតុកកិរិយាចិត្ត ៣ ដួង និងសហេតុកកិរិយាចិត្ត ៨ ដួង អហេតុកកិរិយាចិត្តបានពោលមកហើយ តទៅនេះនឹងពោល សហេតុកកិរិយាចិត្ត ៨ ដួង ចិត្ត ៨ដួងនេះជាចិត្តឱ្យសម្រេចការធ្វើ ការនិយាយ ការគិតរបស់ព្រះអរហន្ត ជាកិរិយាចិត្តដែលចូលដល់ភាព ជាជវនៈសោយអារម្មណ៍ ដែលជាសោមនស្ស ឬ ឧបេក្ខាមិនជាកាលដូច្នោះ លោកទើបប្រៀបធៀបដូច(ផ្កាឈើដែលនៅជាប់ដើម) មានឫសដាច់ហើយសហេតុកចិត្ត ឬហៅថាមហាកិរិយាចិត្ត ជាចិត្តមានហេតុប្រកបទើបកើតឡើងទទួលកាមារម្មណ៍ ជាចំណែកច្រើនកើតបាន ២៦ ភូមិ

( វៀរអបាយ និងអសញ្ញិសត្តាភូមិ ) មហាកិរិយាចិត្តនេះ បើមិនជាមួយព្រះអរហន្ត ក៏ជាចិត្តមហាកុសលនុ៎ះឯង ។

មហាកិរិយាចិត្តរបស់ព្រះអរហន្ត ដែលកើតព្រមដោយសោមនស្សវេទនា រមែងកើតក្នុងទ្វារទាំង ៦ ។ ពិតមែនហើយ ក្នុងចក្ខុទ្វារព្រះខីណាស្រព ឃើញស្ថានដែលគួរបំពេញសេចក្តីព្យាយាមហើយ រមែងដល់ភាពជាសោមនស្សដោយមហាកិរិយាចិត្តដូងនេះក្នុងលោកទ្វារ កាលដល់វារៈដែលលោកគួរចែកចំណែកភណៈ កាលអ្នកល្មោភ ធ្វើសម្លេងខ្លាំងកាន់យក លោកក៏កើតសោមនស្ស ដោយចិត្តនេះថា តណ្ហាជាហេតុឱ្យញាប់ញ័របែបនេះ យើងលះបានហើយ ដោយគ្រឿងក្រអូបឬដោយផ្កាឈើ លោកក៏កើតសោមនស្សដោយចិត្តនេះ ក្នុងជីវ្ហាទ្វារព្រះខីណា-ស្រព បែងចែកបិណ្ឌបាតដែលមានរសឆ្ងាញ់ ដែលបានមកឆាន់ យើងបំពេញហើយហ្ន៎ ! ដូច្នេះក្នុងកាយទ្វារ ព្រះខីណាស្រពបំពេញអភិសមាចារិកវត្ត ក៏ដល់ភាពសោ-មនស្សដោយចិត្តនេះថា វត្តរបស់យើងពេញគ្រប់ហើយ ដូច្នេះ ព្រះខីណាស្រពរមែងមានសោមនស្សក្នុងបញ្ចទ្វារយ៉ាងនេះ ។ តែក្នុងមនោទ្វារចិត្តសោមនស្ស របស់

ព្រះខីណាស្រព រមែងកើតឡើងព្រោះប្រារព្ធអតីត និងអនាគត ។ ពិតមែន ព្រះតថាគតទ្រង់រឭកដល់ហេតុដែលទ្រង់ធ្វើហើយ ក្នុងកាលដែលព្រះអង្គសោយជាតិជាជោតិបាល ជាស្ដេចមឃទេវរាជ និងជាកណ្ហតាបសជាដើម ទើបទ្រង់ធ្វើការញញឹមឱ្យប្រាកដ តែការរឭកនោះជាកិច្ចរបស់បុព្វេនិវាសញ្ញាណ និងសព្វញ្ញុតញ្ញាណ ក្នុងវេលាអស់បំផុតនៃញាណទាំង ២ នោះ ចិត្តដួងនេះរមែងកើតរីករាយក្នុងអនាគត ព្រះអង្គទ្រង់បានធ្វើការញញឹមឱ្យប្រាកដថា និងមានព្រះបច្ចេកពុទ្ធ មានសម្លេងដូចពិលាមានសម្លេងដូចសម្ភោរដូច្នោះ ។ ការរឭកនោះ ជាកិច្ចរបស់អនាគតំសញ្ញាណ និងសព្វញ្ញុតញ្ញាណ ក្នុងវេលាអស់បំផុតនៃញាណទាំង ២ នោះ ចិត្តដួងនោះរមែងកើតរីករាយ ។

មហាកិរិយាចិត្ត ដែលកើតព្រមនិងឧបេក្ខាវេទនា នោះរមែងប្រាកដ ក្នុងខណៈដែលលោកពិចារណា អារម្មណ៍ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង ៦ ដោយឆឡង្គុបេក្ខា មិនមានសេចក្ដីញាប់ញ័រយ៉ាងណាទេ ។ មួយទៀត មហាកិរិយាចិត្ត របស់ព្រះខីណាស្រពនោះ គ្រាខ្លះក៏ប្រកបដោយ

ញាណ គ្រាខ្លះក៏មិនប្រកបដោយញាណ ដែលមិនប្រកបដោយញាណ ដូចក្នុងខណៈឈរ ដើរ ជាដើម មិនបាច់មានបញ្ញា ក៏ឈរ ដើរ អង្គុយ សឹងបាន។

**ជំនួយសុខភាពផ្លូវចិត្ត ភាគ ៣**



# ស្ថានីយ៍វិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដែលសំដែងដោយ ខ្ញុំព្រះករុណា_អាត្មាភាព ចាន់ សុជន

| ខេត្ត_ក្រុង | វេលាផ្សាយ | ស្ថានីយ៍វិទ្យុ |
|---|---|---|
| បន្ទាយមានជ័យ | ៥:៣០ ព្រឹក<br>៨:០០ ល្ងាច (សៅរ៍_អាទិត្យ)<br>បន្តផ្ទាល់ពីប្រទេស ស្រីលង្កា | FM ៩៩ MHz |
| កំពង់ធំ | ៥:៣០ ព្រឹក | FM ៩៨.៣ MHz |
| ឧត្តរមានជ័យ | ៥:៣០ ព្រឹក | FM ៩០.៥ MHz |

**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទានឈ្នះអស់ទានទាំងពួង**




ចេះធ្វើអំពើល្អ ប្រសើរជាងចេះធ្វើអ្វីៗទាំងពួង

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹង ដោយការមិនខឹងតប គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ ដោយការឲ្យទាន គប្បីឈ្នះមនុស្សឡេះឡោះឥតបានការ ដោយការនិយាយពាក្យពិតមានប្រយោជន៍ ។